១៣- អនុសេនីយ៍ទោ **ម៉ន សុគ្រាស**
១៤- អនុសេនីយ៍ទោ **ឆេង សោភ័ណ្ឌ**
១៥- អនុសេនីយ៍ត្រី **ណុប មនោ**
១៦- លោកវេជ្ជបណ្ឌិត **ស៊ីសុទ្ធ អមត្ថា**
១៧- លោកវេជ្ជបណ្ឌិត **សារុន សារាមុនី**
១៨- លោកវេជ្ជបណ្ឌិត **ជា យុទ្ធារុណ**
១៩- លោកវេជ្ជបណ្ឌិត **តាង ពិសិដ្ឋ**
២០- លោកស្រីវេជ្ជបណ្ឌិត **ឡៀប ពិណោ**
២១- លោកវេជ្ជបណ្ឌិត **ជួរ ម៉េង**
២២- លោក **ម៉ី សារ៉ែន**
២៣- លោក **ហេង ឆន**
២៤- លោក **ហ៊ឹង រ័ត្ន**
២៥- លោក **សំ ម៉ឹង**
២៦- លោកស្រី **គុន គន្ធី**
២៧- លោក **ស៊ុយ វណ្ណនី**
២៨- លោក **ជិន វិចិត្រ**
២៩- លោក **ម៉េង ចារ័ត្ន**
៣០- លោកវេជ្ជបណ្ឌិត **សំ ប៊ូរ៉ែន**
៣១- លោកវេជ្ជបណ្ឌិត **ហេង លី**
៣២- លោកវេជ្ជបណ្ឌិត **ជ គុនី**
៣៣- លោកវេជ្ជបណ្ឌិត **ហាម ឡុង**
៣៤- លោកស្រីវេជ្ជបណ្ឌិត **លឹម ពៅ**
៣៥- លោកវេជ្ជបណ្ឌិត **ឈុន ឡាយ**
៣៦- លោកវេជ្ជបណ្ឌិត **ណៃ តារារិទ្ធ**
៣៧- លោកវេជ្ជបណ្ឌិត **ជិន កែវសុវណ្ណ**
៣៨- លោកវេជ្ជបណ្ឌិត **អ៊ុយ ឈួង**
៣៩- កញ្ញា **ពុត ឡៃហេង**
៤០- លោកវេជ្ជបណ្ឌិត **សៅ សុគន្ធណា**
៤១- លោកស្រីវេជ្ជបណ្ឌិត **សុខ សុខេម**
៤២- លោក **ជួង សាវ៉ាន**
៤៣- លោក **មុត ស៊ីថា**

ជ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ :**

១- លោក **ឯម សុខុម**
៥- លោក **ខៀវ នួន**

២- អនុសេនីយ៍ឯក **សុខ សុវណ្ណ**
៣- អនុសេនីយ៍ឯក **លី អ៊ីចំរើន**
៤- អនុសេនីយ៍ឯក **អ៊ុន សុផល**
៦- អនុសេនីយ៍ទោ **ស៊ិន កុសល្យ**
៧- អនុសេនីយ៍ត្រី **តូច តង្ក្រា**
៨- លោក **សួន សុខុយ**

ឈ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ :**

១- អនុសេនីយ៍ឯក **ខេង ស៊ុនដារុឡា**
២- អនុសេនីយ៍ទោ **ស៊ីន ប៊ុនអាន**
៣- អនុសេនីយ៍ត្រី **ម៉ាន់ សារឿន**

ញ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា :**

១- អនុសេនីយ៍ឯក **អ៊ុន សុផល**
២- លោក **អ៊ុំ សារអាត**
៣- លោកស្រី **ច្រឹង សំអាត**
៤- លោក **អ៊ុច សាផន**
៥- លោក **ប៉ែន ចាន់ថន**
៦- អនុសេនីយ៍ទោ **ស៊ិន រ៉ាឌុធ**
៧- អនុសេនីយ៍ត្រី **ហេង ចំណាប់**
៨- លោក **មូល ម៉ាឡៃ**
៩- លោក **មាស សុវណ្ណ**
១០- លោក **ឯម ធា**

ដ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ :**

១- លោកទន្តបណ្ឌិត **សៅ សុតាព៉ា**
២- លោកទន្តបណ្ឌិត **គួច បូតា**
៣- លោកទន្តបណ្ឌិត **ប៊ុន គឹមចៅ**
៤- លោក **នួន ចាន់ធឿន**
៥- លោកវេជ្ជបណ្ឌិត **ថាន់ ស៊ីថា**
៦- លោកស្រី **ស៊ឹម ស៊ីនេត**
៧- កញ្ញាឱសថការី **កឿន ពុទ្ធិតា**
៨- លោក **កុយ រី**
៩- លោក **ហែម សុបុត្រា**
១០- លោក **ទេព សុផល**
១១- លោកទន្តបណ្ឌិត **ហ៊ីង ហុងសៀង**
១២- លោក **ប៊ុត នឿន**
១៣- លោក **ពេជ អូន**
១៤- លោក **សំ ណាង**
១៥- លោក **អុន កាថន**
១៦- លោកស្រីទន្តបណ្ឌិត **ឡាយ រ៉ាទី**
១៧- លោកទន្តបណ្ឌិត **ឈួយ គីមឡុង**
១៨- លោកស្រី **ឃឹម ចន្ថា**
១៩- លោកស្រីវេជ្ជបណ្ឌិត **ហេង យ៉ារី**
២០- លោកវេជ្ជបណ្ឌិត **ទើក វ៉ាស៊ីម**
២១- លោកស្រី **ជាង លីណា**
២២- កញ្ញា **ហ៊ឹម ម៉ារ៉ានី**
២៣- លោក **សេង ដារ៉ា**
២៤- លោក **ហុក គឿរ**
២៥- លោកឱសថការី **លឿង នួយ**
២៦- លោកទន្តបណ្ឌិត **ឆន មករា**
២៧- លោក **សៀង យ៉ុក**
២៨- លោក **គិន រដ្ឋា**
២៩- លោកស្រី **អ៊ុន សូរ**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នរស. ១៤០៨.១១០៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤*

លេខៈ ១១២៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៥១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា២ថ្មី នៃអនុក្រឹត្យលេខ៩៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៥ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- បានឃើញអនុក្រឹត្យលេខ៥៧អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៩៩អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រាមួយ .-**

មាត្រា២ថ្មី នៃអនុក្រឹត្យលេខ៩៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ត្រូវបានកែសម្រួលដូចតទៅ៖

**មាត្រា២ .-ថ្មី (មួយ)**

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ជាយន្តការអន្តរក្រសួង មានចរិតលក្ខណៈអន្តរវិស័យ និងពហុជំនាញ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| ២-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | ប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | មួយ (០១) រូប | អនុប្រធាន |
| ៤-រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | មួយ (០១) រូប | អនុប្រធាន |
| ៥-រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | មួយ (០១) រូប | អនុប្រធាន |
| ៦-រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | មួយ (០១) រូប | សមាជិក |
| ៧-អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | មួយ (០១) រូប | សមាជិក |
| ៨-អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | មួយ (០១) រូប | សមាជិក |
| ៩- អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | មួយ (០១) រូប | សមាជិក |
| ១០-អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | មួយ (០១) រូប | សមាជិក |
| ១១-អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | មួយ (០១) រូប | សមាជិក |
| ១២-អនុរដ្ឋលេខាធិការក្រសួងផែនការ | មួយ (០១) រូប | សមាជិក |
| ១៣-អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | មួយ (០១) រូប | សមាជិក |
| ១៤-អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | មួយ (០១) រូប | សមាជិក |
| ១៥-អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | មួយ (០១) រូប | សមាជិក |
| ១៦-អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | មួយ (០១) រូប | សមាជិក |
| ១៧-អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | មួយ (០១) រូប | សមាជិក |
| ១៨-អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | មួយ (០១) រូប | សមាជិក |
| ១៩-អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | មួយ (០១) រូប | សមាជិក |
| ២០-អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | មួយ (០១) រូប | សមាជិក |
| ២១-អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | មួយ (០១) រូប | សមាជិក |
| ២២-អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | មួយ (០១) រូប | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ១.៣៧៧,២៣ ហិកតា នៅស្រុកព្រៃកប្របសព្វ ខេត្តក្រចេះ ក្នុងនោះ កាត់ចេញពីដីតម្របព្រៃឈើឆ្នាំ ២០០២ កាត់ចេញពីដីមានដីភាជកហ្មត និងកាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន Timas Resources LTD និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិ-បុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្ដីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៣៣៨ ល.ក្រច ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៤ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- លិខិតលេខ ៣៣៩ ល.ក្រច ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៤ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ១.៣៧៧,២៣ ហិកតា ក្នុងនោះ (១)ទំហំ ៦៥៦,៣៨ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (២)ទំហំ ២៧២,៨៤ហិកតា កាត់ចេញពីដីមានដីកាដកហូត និង (១)ទំហំ ៤៤៨,០១ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន Timas Resources LTD និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ១.២៥៣,០១ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង និងទំហំ ១២៤,២២ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិព្រែករកា ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង នៅភូមិព្រែករកា ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើ ៨៥៦ ក្បាលដី ជូនប្រជាពលរដ្ឋ ៣១០ គ្រួសារ នៅភូមិព្រៃករកា ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៥៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៤៣១,១៦ ហិកតា នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃនីញ សៀមរាបអភិវឌ្ឍន៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៣៥៣ លស/ឧជ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៤ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តឧត្តរមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៤៣១,១៦ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃនីញ សៀមរាបអភិវឌ្ឍន៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៣៨៣,៧០ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៤៧,៤៦ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិអូរក្រូច ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃ អនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិអូរក្រូច ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដី ១០៤ ក្បាលដី ជូនប្រជាពលរដ្ឋ ៩០ គ្រួសារ

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង   គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ  រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់   រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម  រុក្ខាប្រមាញ់ និងនេសាទ  រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ  ថ្ងៃទី ១៨  ខែ កញ្ញា  ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ២២០,៥៩ ហិកតា នៅស្រុកព្រៃកប្រសព្វ ខេត្តក្រចេះ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៣៤០ ល.ក្រច ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៤ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- លិខិតលេខ ៣៤១ ល.ក្រច ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៤ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីទំហំ ២២០,៥៩ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ២០៣,៥០ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ១៧,០៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិសោបលើ ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិសោបលើ ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើ ៤១ ក្បាលដី ជូនប្រជាពលរដ្ឋ ៣១ គ្រួសារ នៅភូមិសោបលើ ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

**មាត្រា ៤:** ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៩.៦៦៦,៥២ ហិកតា នៅស្រុកព្រៃកប្រសព្វ ខេត្តក្រចេះ ក្នុងនោះ កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ កាត់ចេញពីដីមានដីភោគកម្ម និងកាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន TIMAS RESOURCE LTD និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៣៩២ ល.ក្រច ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៤ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- លិខិតលេខ ៣៩២ ល.ក្រច ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៤ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ៩.៦៦៦,៥២ ហិកតា ក្នុងនោះ និង(១)ទំហំ ១.២១០,៣៣ហិកតា កាត់ចេញ ពីដីគម្របព្រៃឈើឆ្នាំ២០០២ (២) ទំហំ៥.៤៧២,០១ហិកតា កាត់ចេញពីដីមានដីកាដកហូត និង(៣) ទំហំ ២.៩៨៤,១៨ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន TIMAS RESOURCE LTD និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៨.៣៩៥,៨២ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ១.២៧០,៧០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិសោបក្រោម ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិសោបក្រោម ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

**មាត្រា ៣:** ផ្តល់សិទ្ធិជាកម្មសិទ្ធិ ២.១៩៣ ក្បាលដី ក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិលើ ២.១៨៨ ក្បាលដី ជូនប្រជាពលរដ្ឋ ១.៨៥០ គ្រួសារ និងចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋចំនួន០៥ក្បាលដី (ដីសាលារៀន ០១ក្បាលដី និងដីសាលាឃុំ ០៤ក្បាលដី) នៅភូមិសោបក្រោម ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

**មាត្រា ៤:** ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ផ្ទៃដីសរុបទំហំ ៧.១១១,៨១ ហិកតា នៅស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ក្នុងនោះ កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ កាត់ចេញពីដីមានដីកាដកហូត កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន Timas Resources LTD និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៤៥០ ល.ក្រច ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៤ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៧.១១១,៨១ ហិកតា ក្នុងនោះ (១) ទំហំ ៣១៥,០១ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (២)ទំហំ ៩៦៦,៥៣ ហិកតា កាត់ចេញពីដីមានដីកាដកហូត និង(៣) ទំហំ ៥.៨៣០,២៧ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន Timas Resource LTD និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៦.២៩២,៩០ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៨១៨,៩១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រែកប្រសព្វលើ ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិព្រែកប្រសព្វលើ ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

**មាត្រា ៣**: ផ្តល់សិទ្ធិជាកម្មសិទ្ធិ ២.២៥៦ ក្បាលដី ក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិលើ ២.២៤២ ក្បាលដី ជូនប្រជាពលរដ្ឋ ១.៣៤៤ គ្រួសារ និងចុះបញ្ជីជាដីរបស់សាធារណៈរបស់រដ្ឋចំនួន ១៤ ក្បាលដី (ដីសាលារៀន ០២ក្បាលដី ត្រពាំង ១០ក្បាលដី និងដីប៉ុស្តិ៍រដ្ឋបាល ០២ក្បាលដី) នៅភូមិព្រែកប្រសព្វលើ ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៧៥៧..អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅ
# នៃគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៤

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

ត្រូវបានបង្កើតឡើងនូវគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ ដែលសរសេរជាអក្សរកាត់ថា **គ.ជ.ម.ព.**។

## ជំពូកទី២
## សមាសភាព

**មាត្រា២ ..**

**គ.ជ.ម.ព.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៦. តំណាងក្រសួងការពារជាតិ | សមាជិក |
| ៧. តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨. តំណាងក្រសួងផែនការ | សមាជិក |
| ៩. តំណាងក្រសួងបរិស្ថាន | សមាជិក |
| ១០. តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១១. តំណាងក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១២. តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៣. តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១៤. តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៥. តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៦. តំណាងធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១៧. តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ១៨. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៩. តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ២០. តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ២១. ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិកនិងជាប្រធានលេខាធិការដ្ឋាន |

សមាសភាពជាក់ស្តែងនៃ **គ.ជ.ម.ព.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ គ.ជ.ម.ព.

**មាត្រា៣ .-**

**គ.ជ.ម.ព.** មានតួនាទីនិងភារកិច្ចដូចតទៅៈ

- ប្រមូល ចាត់ថ្នាក់ ពិនិត្យឡើងវិញ និងធ្វើឱ្យប្រសើរឡើងនូវរាល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃវិធានការមិនមែនពន្ធ ដូចដែលបានកំណត់ដោយអង្គការសន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ (UNCTAD)
- ធ្វើបច្ចុប្បន្នកម្ម ផ្សព្វផ្សាយ និងរក្សាទុករាល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃវិធានការមិនមែនពន្ធ
- រៀបចំគោលការណ៍ណែនាំអនុវត្ត ប្រសិនបើជាការចាំបាច់ឬធ្វើឱ្យប្រសើរឡើងនូវគោលការណ៍ណែនាំអនុវត្តដែលមានស្រាប់ ដើម្បីធានាថាការអនុវត្តមិនរឹតត្បិតជាងសេចក្តីត្រូវការ
- វាយតម្លៃនិងកែសម្រួលឡើងវិញនូវវិធានការមិនមែនពន្ធ ដើម្បីកាត់បន្ថយជាអតិបរមា ការរឹតត្បិតទៅលើការធ្វើពាណិជ្ជកម្មនិងវិនិយោគ
- កំណត់សមាសភាពរឹតត្បិតដែលមិនចាំបាច់នៃវិធានការមិនមែនពន្ធ និងលើកសំណើសុំកែប្រែ ឬលុបសមាសភាពទាំងនោះជូនរាជរដ្ឋាភិបាល ដើម្បីធានាអនុលោមភាពជាមួយបណ្តាកិច្ចព្រមព្រៀងតំបន់និងអន្តរជាតិ
- ជូនព័ត៌មានអំពីវិធានការមិនមែនពន្ធទៅអង្គការពាណិជ្ជកម្មពិភពលោកតាមរយៈក្រសួងពាណិជ្ជកម្មនិងទៅលេខាធិការដ្ឋានអាស៊ាន តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- វាយតម្លៃអំពីការលំបាកនានាក្នុងកិច្ចដំណើរការរបស់ស្ថាប័ននិងកៀរគរធនធានហិរញ្ញវត្ថុដើម្បីពង្រឹងសមត្ថភាពស្ថាប័ននិងមន្ត្រី
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធានាសង្គតិភាព ប្រសិទ្ធភាព និងពង្រឹងកិច្ចសហប្រតិបត្តិការ
- ទទួលនិងប្រើប្រាស់ហិរញ្ញប្បទានពីបណ្តាប្រទេសដទៃទៀត អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា ពាក់ព័ន្ធនឹងការធ្វើឱ្យប្រសើរឡើងនូវវិធានការមិនមែនពន្ធ
- ផ្តល់អនុសាសន៍តាមការចាំបាច់និងរៀបចំរបាយការណ៍បូកសរុបការងារប្រចាំឆ្នាំអំពីវឌ្ឍនភាពការងារជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.ម.ព.

**មាត្រា៤ .-**

**គ.ជ.ម.ព.** ត្រូវរៀបចំនីតិវិធីប្រតិបត្តិនិងផែនការការងារប្រចាំឆ្នាំរបស់ខ្លួន។

**មាត្រា៥ .-**

**គ.ជ.ម.ព.** ត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការក្នុងការបំពេញមុខងាររបស់ខ្លួនដូចមានចែងក្នុងមាត្រា៣និងមាត្រា៤ខាងលើ។ នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាននៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបំពេញមុខងារជាលេខាធិការដ្ឋានរបស់ **គ.ជ.ម.ព.**។

លេខាធិការដ្ឋាន **គ.ជ.ម.ព.** អាចស្នើសុំយោបល់ពីក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬស្ថាប័ន អង្គភាពប្រឹក្សាច្បាប់ផ្សេងទៀត អំពីសេចក្តីព្រាងសំណើសុំកែប្រែវិធានការមិនមែនពន្ធឬលុបបំបាត់វិធានការមិនមែនពន្ធ។

ក្រសួង ស្ថាប័ននីមួយៗដូចបានរៀបរាប់ខាងលើ ត្រូវកំណត់ចំណុចទំនាក់ទំនង និងត្រូវជូនព័ត៌មានអំពីការចាត់នេះ ជាលាយលក្ខណ៍អក្សរមកលេខាធិការដ្ឋាននៃ **គ.ជ.ម.ព.**។ រាល់ការផ្លាស់ប្តូរចំណុចទំនាក់ទំនងត្រូវជូនព័ត៌មានជាបន្ទាន់និងជាលាយលក្ខណ៍អក្សរ មកលេខាធិការដ្ឋាននៃ **គ.ជ.ម.ព.**។

**មាត្រា៦ .-**

ក្រសួង ស្ថាប័នដែលរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការមិនមែនពន្ធអាចអញ្ជើញតំណាងលេខាធិការដ្ឋានឱ្យចូលរួមរៀបចំ ហើយត្រូវបញ្ជូនសេចក្តីព្រាងនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនោះមក **គ.ជ.ម.ព.** ដើម្បីធានានូវអនុលោមភាពទៅនឹងច្បាប់ជាធរមានរបស់កម្ពុជានិងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងអន្តរជាតិនិងតំបន់ដែលកម្ពុជាជាភាគី។ **គ.ជ.ម.ព.** ត្រូវពិនិត្យនិងឆ្លើយតបទៅសាមីក្រសួង ស្ថាប័នក្នុងរយៈពេលយ៉ាងយូរ៩០(កៅសិប)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ចំពោះច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានានៃវិធានការមិនមែនពន្ធដែលមានស្រាប់ **គ.ជ.ម.ព.** ត្រូវត្រួតពិនិត្យឡើងវិញដើម្បីធានានូវអនុលោមភាពទៅនឹងកាតព្វកិច្ច ក្រោមកិច្ចព្រមព្រៀងអន្តរជាតិនិងតំបន់ ដែលកម្ពុជាជាភាគី។ ក្នុងករណីចាំបាច់ **គ.ជ.ម.ព.** អាចស្នើឱ្យក្រសួង ស្ថាប័នសាមីត្រួតពិនិត្យនិងកែសម្រួលឡើងវិញនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានានៃវិធានការមិនមែនពន្ធដែលរកឃើញថាមិនមានអនុលោមភាពទៅនឹងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងអន្តរជាតិនិងតំបន់ដែលកម្ពុជាជាភាគី។

ក្នុងករណីបន្ទាន់និងមានភស្តុតាងពេញលេញ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានានៃវិធានការមិនមែនពន្ធអាចអនុវត្តបានដោយក្រសួងសាមីជាមុននិងត្រូវធ្វើការត្រួតពិនិត្យដោយ **គ.ជ.ម.ព.** ជាក្រោយ។ ក្នុងករណីនេះ ក្រសួងសាមីដែលបានអនុម័តវិធានការដូចខាងលើ ត្រូវជូនព័ត៌មានអំពីការអនុវត្តជាបន្ទាន់ មក **គ.ជ.ម.ព.**។

**មាត្រា៧ .-**

សមាជិកនៃ **គ.ជ.ម.ព.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធាន **គ.ជ.ម.ព.** ត្រូវដឹកនាំអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានត្រូវអញ្ជើញនិងដឹកនាំកិច្ចប្រជុំជំនួស។

ប្រធាន **គ.ជ.ម.ព.** អាចអញ្ជើញអ្នកជំនាញនិងតំណាងក្រសួង ស្ថាប័នដែលមិនមែនជាសមាជិកនៃ **គ.ជ.ម.ព.** ចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា៨ .-**

**គ.ជ.ម.ព.** ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដងក្នុង១(មួយ)ឆ្នាំ។

ក្នុងករណីចាំបាច់ **គ.ជ.ម.ព.** អាចប្រជុំជាវិសាមញ្ញ តាមការកោះអញ្ជើញរបស់ប្រធាន។

**មាត្រា៩ .-**

**គ.ជ.ម.ព.** មានសិទ្ធិប្រើត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញការងាររបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធាននិងមូលនិធិ

**មាត្រា១០ .-**

ការចំណាយសម្រាប់ដំណើរការ **គ.ជ.ម.ព.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ.ជ.ម.ព.** មានសិទ្ធិទទួលនិងចាត់ចែង ប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩៤១ អនក្រ.តត

# អនុក្រឹត្យ

**ស្តីពី**

**ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិជាន់ខ្ពស់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **ម៉ិល សារិន** អត្តលេខ ០៦៦៥១ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សម្រេច**

**មាត្រា ១** : ប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៃក្រសួងធម្មការ និងសាសនា ចំនួន ៦ រូបៈ

១- លោក **សាយ អំណាន** ឲ្យបំពេញមុខងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការសាសនា ជំនួសលោកស្រី មិន ចណ្ឌីណែត ដែលត្រូវទទួលភារកិច្ចថ្មី ។

២- លោក **ខួន សុវណ្ណារ៉ា** ឲ្យបំពេញមុខងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ។

៣- លោក **មិន ម៉ាដេត** ឲ្យបំពេញមុខងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ។

៤- លោក **ខ៊ែត ច័ន្ទម៉ុរ** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានកិច្ចការព្រះពុទ្ធសាសនា ជំនួសលោកស្រី **ស្រី ស៊ីលីម** ដែលត្រូវបានចូលនិវត្តន៍ ។

៥- លោក **ខុន តារា** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានពាហិរសាសនា ជំនួសលោកស្រី **យឹម យូដាវណ្ណ** ដែលត្រូវបានចូលនិវត្តន៍ ។

៦- លោក **ស សុខនី** ឲ្យបំពេញមុខងារជាប្រធានពុទ្ធសាសនបណ្ឌិត្យ ថ្នាក់ស្មើប្រធាននាយកដ្ឋាន ជំនួសលោកស្រី **ឃិន ចំរើន** ដែលត្រូវបានចូលនិវត្តន៍ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩៤៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ដាក់លោក **ឃន យ៉យ** មុខតំណែងនាយកសាលាមធ្យមវិចិត្រសិល្បៈ ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៤ តទៅ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ [illegible] ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ៣៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងសង្គមកិច្ច នៅ**វត្តសិរីទិ្ធមានជ័យ** ស្ថិតនៅក្នុងឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច នៅ**វត្តសម្តេច ឧន្ទ ង៉ែត សែនជ័យសព្វារាម** និង**វត្តពលិសបព្វតារាម** ស្ថិតនៅក្នុងឃុំស្ទិប និងឃុំស្រែថ្មី ស្រុករលាប្អៀរ និងនៅ**វត្តពោធិសិលារាម** ស្ថិតនៅក្នុងសង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ២៩ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **សូ ចាន់ស៊ីម** | ព្រះចៅអធិការវត្តពលិសបព្វតារាម | បច្ច័យចំនួន ១៣.២១០ ដុល្លារ |
| ២-ព្រះតេជគុណ | **ស៊ុន សូនីសក្តិ** | ប្រធានសមាគមជំរុំយុវខេមរា | បច្ច័យចំនួន ១១.១២០ ដុល្លារ |
| ៣-ព្រះតេជគុណ | **វណ្ណ សាវតារ** | ទីប្រឹក្សាសមាគមជំរុំយុវខេមរា | បច្ច័យចំនួន ១១.១០០ ដុល្លារ |
| ៤-ព្រះតេជគុណ | **រិន ផល្លា** | ទីប្រឹក្សាសមាគមជំរុំយុវខេមរា | បច្ច័យចំនួន ១១.១០០ ដុល្លារ |
| ៥-ព្រះតេជគុណ | **ម៉ែន សេដ្ឋា** | ព្រះគ្រូសូត្រស្តាំវត្តពលិសបព្វតារាម | បច្ច័យចំនួន ១១.០៥០ ដុល្លារ |
| ៦-ព្រះតេជគុណ | **ស្រី កេនណារ័ត្ន** | គង់នៅវត្តទេពធីតារាម | បច្ច័យចំនួន ១០.១៥០ ដុល្លារ |
| ៧-ព្រះតេជគុណ | **ផាន់ សុខសល** | ព្រះគ្រូសូត្រស្តាំវត្តពោធិសិលារាម | បច្ច័យចំនួន ១០.១៣៥ ដុល្លារ |
| ៨-លោកស្រី | **អៀង ម៉ាន់ឡាយ** | ប្រធានសមាគមសមាធិព្រះពុទ្ធសាសនាអន្តរជាតិ | ថវិកាចំនួន ១១.៥៨៥ ដុល្លារ |
| ៩-លោក | **ម៉ា រិន** | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ១១.២០០ ដុល្លារ |
| ១០-ឧបាសិកា | **ហ៊ន ម៉ាន់ឌី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.១៥០ ដុល្លារ |
| ១១-លោក | **ថ្លាំ គុំ** | ប្រធានគណៈកម្មការវត្តសិរីទិ្ធមានជ័យ | ថវិកាចំនួន ១១.១១០ ដុល្លារ |
| ១២-លោក | **សែម យ៉ិន** | ប្រធានគណៈកម្មការវត្តពលិសបព្វតារាម | ថវិកាចំនួន ១១.០៥០ ដុល្លារ |

| | | | |
|---|---|---|---|
| ១៣-លោក **ប៊ុត ឆ្នូក** | គណៈកម្មការវត្តសិរិទ្ធិមានជ័យ | ថវិកាចំនួន | ១១.០០០ ដុល្លារ |
| ១៤-លោក **ជុំ សំអាត** | មន្ត្រីធម្មការខេត្ត | ថវិកាចំនួន | ១០.១៥០ ដុល្លារ |
| ១៥-លោក **គាំ ហ៊ី** | អាចារ្យវត្តសិរិទ្ធិមានជ័យ | ថវិកាចំនួន | ១០.១៥០ ដុល្លារ |
| ១៦-លោក **គាំ សារុន** | អាចារ្យវត្តសិរិទ្ធិមានជ័យ | ថវិកាចំនួន | ១០.១៥០ ដុល្លារ |
| ១៧-លោក **អ៊ូ ម៉ាច** | គណៈកម្មការវត្តសិរិទ្ធិមានជ័យ | ថវិកាចំនួន | ១០.១៥០ ដុល្លារ |
| ១៨-លោក **រិត ថា** | សមាជិកគណៈកម្មការវត្តសិរិទ្ធិមានជ័យ | ថវិកាចំនួន | ១០.១៥០ ដុល្លារ |
| ១៩-កញ្ញា **យិន សុខុម** | មន្ត្រីធម្មការស្រុក | ថវិកាចំនួន | ១០.១៣០ ដុល្លារ |
| ២០-លោកស្រី **ម៉ម ឡាដែត** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១០.១២៥ ដុល្លារ |
| ២១-ឧបាសិកា **ប៊ុន សុគៀន** | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន | ១០.១២០ ដុល្លារ |
| ២២-ឧបាសិកា **ឡុង ពៅ** | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន | ១០.១២០ ដុល្លារ |
| ២៣-ឧបាសិកា **ឃួន សុខចំរើន** | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន | ១០.១១៥ ដុល្លារ |
| ២៤-លោកស្រី **ផា រី** | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន | ១០.១១០ ដុល្លារ |
| ២៥-លោក **ខុន ខេមរា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១០.១១០ ដុល្លារ |
| ២៦-ឧបាសិកា **ទ្រី មៀន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១០.០១៥ ដុល្លារ |
| ២៧-ឧបាសិកា **តួន ឈុយអេង** | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន | ១០.១២០ ដុល្លារ |
| ២៨-លោក **យូ ចាំសារួន** | មេឃុំកំពង់ត្រឡាច | ថវិកាចំនួន | ១០.០១០ ដុល្លារ |
| ២៩-លោក **ចាន់ ចាត់** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១០.០១០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៧ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ **ស៊ឹម សុខចំរើន** | ព្រះគ្រូសូត្រឆ្វេងវត្តពោធិសិលារាម | បច្ច័យចំនួន | ៧.២១០ ដុល្លារ |
| ២-លោក **ជួន សុថុន** | គណៈកម្មការវត្តពោធិសិលារាម | ថវិកាចំនួន | ៧.១០០ ដុល្លារ |
| ៣-លោក **អ៊ុង សាមៀន** | គណៈកម្មការវត្តពោធិសិលារាម | ថវិកាចំនួន | ៦.៥០០ ដុល្លារ |
| ៤-លោក **គ្រុំ ស៊ន** | គណៈកម្មការវត្តពោធិសិលារាម | ថវិកាចំនួន | ៦.៣៥០ ដុល្លារ |
| ៥-លោក **អ៊ឹម ឆន** | គណៈកម្មការវត្តពោធិសិលារាម | ថវិកាចំនួន | ៦.៣១០ ដុល្លារ |
| ៦-លោក **នាង បូរ** | គណៈកម្មការវត្តពោធិសិលារាម | ថវិកាចំនួន | ៦.១៥០ ដុល្លារ |
| ៧-លោក **តុន ត្រឹម** | គណៈកម្មការវត្តពោធិសិលារាម | ថវិកាចំនួន | ៦.១១០ ដុល្លារ |

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ០៩ ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះតេជគុណ **សាត សុខលី** ព្រះគ្រូសូត្រឆ្វេងវត្តសម្តេច **នន្ទ ង៉ែត** សែនជ័យសត្ថារាម ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា នៅក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តសម្តេច នន្ទ ង៉ែត** សែនជ័យសត្ថារាម ស្ថិតនៅក្នុងឃុំស្ទិប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង *ចំណាយអស់ថវិកាសរុបចំនួន ៣១.១០០ ដុល្លារ ។*

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៩៤៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេស ចំនួន ៣៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានានៅក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តកោះជុំ វត្តវេឡុវ័ន** (ហៅវត្តដំណាក់ត្រាច) **វត្តសិរីពោធិ៍មង្គល** (ហៅវត្តស្រះម្កាក់) **វត្តឧត្តមរុក្ខារាម** (ហៅវត្តដំណាក់ធ្នង់) ស្ថិតនៅក្នុងឃុំត្នោតជុំ ឃុំអូរតាប៉ោង និងឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលមានវាយព្រះនាម និងនាមដូចខាងក្រោម :

**ក~ មេដាយមាសស្ថាបនាជាតិចំនួន ១៣ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណធម្មធរោ **លី លឿម** ព្រះចៅអធិការវត្តសិរីពោធិ៍មង្គល បច្ច័យចំនួន ១១.៣១៥ ដុល្លារ

២-ព្រះតេជគុណធម្មស្សរោ **គុប ផាត** ព្រះចៅអធិការវត្តឧត្តមរុក្ខារាម បច្ច័យចំនួន ១០.៨៧៥ ដុល្លារ

៣-ព្រះតេជគុណវិរិយបញ្ញោ **ខឹម សាម៉ន** ព្រះចៅអធិការវត្តវេឡុវ័ន្ត បច្ច័យចំនួន ១០.៦២៥ ដុល្លារ

៤-ព្រះតេជគុណបញ្ញាធរោ **សឿក សុវណ្ណ** ព្រះចៅអធិការវត្តកោះជុំ បច្ច័យចំនួន ១០.០៥០ ដុល្លារ

៥-លោក **ឃ៉ាត់ សុជាតិ** សប្បុរសជនខ្មែររស់នៅប្រទេសបារាំង ថវិកាចំនួន ១២.២០០ ដុល្លារ

៦-លោក **គង់ ថន** ប្រធានគណៈកម្មការវត្តសិរីពោធិ៍មង្គល ថវិកាចំនួន ១១.២៥០ ដុល្លារ

៧-ឧបាសិកា **អ៊ិន នឿន** សប្បុរសជននៅខេត្តពោធិ៍សាត់ ថវិកាចំនួន ១០.៤៥០ ដុល្លារ

៨-លោកវរសេនីយ៍ទោ **សោម ថាយ** នាយការិយាល័យទីពាកងពលអន្តរាគមន៍លេខ១៤ ថវិកាចំនួន ១០.៣០០ ដុល្លារ

៩-លោក **អ៊ុក មួន** មេឃុំរំលេច ថវិកាចំនួន ១០.៣០០ ដុល្លារ

| | | | |
|---|---|---|---|
| ១០-លោក **ចៀប ខែម** | មេឃុំត្នោតជុំ | ថវិកាចំនួន | ១០.១៦០ ដុល្លារ |
| ១១-លោក **ចាប សុខឿន** | ជំទប់ទី១ឃុំត្នោតជុំ | ថវិកាចំនួន | ១០.១៥០ ដុល្លារ |
| ១២-ឧបាសក **ម៉ៅ គឹម** | អាចារ្យវត្តវេទ្យាវ័ន | ថវិកាចំនួន | ១០.១២០ ដុល្លារ |
| ១៣-លោក **អ៊ឹម ម៉ុនសឿន** | ជំទប់ទី១ឃុំអូរតាប៉ោង | ថវិកាចំនួន | ១០.១០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ១៧ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក **អោម ទី** | មេភូមិបត់គគីរថ្មី | ថវិកាចំនួន | ៥.៤៥០ ដុល្លារ |
| ២-លោក **ឌីម ឌន** | គណៈកម្មការវត្តសិរីពោធិ៍មង្គល | ថវិកាចំនួន | ៥.៤០០ ដុល្លារ |
| ៣-លោក **ឌុក សារុន** | អាចារ្យវត្តកោះជុំ | ថវិកាចំនួន | ៥.៣០០ ដុល្លារ |
| ៤-លោក **គង់ ដាវន់** | ប្រធានគណៈកម្មការវត្តវេទ្យាវ័ន្ត | ថវិកាចំនួន | ៥.២៥០ ដុល្លារ |
| ៥-លោក **ហ៊ិន យាន** | អនុប្រធានគណៈកម្មការវត្ត | ថវិកាចំនួន | ៥.២២០ ដុល្លារ |
| ៦-ឧបាសក **ឆាន គោគ** | ប្រធានអាចារ្យវត្តឧត្តមរុក្ខារាម | ថវិកាចំនួន | ៥.១៣០ ដុល្លារ |
| ៧-ឧបាសក **ខៀវ អឹម** | សមាជិកក្រុមប្រឹក្សាឃុំខ្នារទទឹង | ថវិកាចំនួន | ៥.១១៥ ដុល្លារ |
| ៨-លោក **ខេង ម៉ុច** | ប្រធានអាចារ្យវត្តឧត្តមរុក្ខារាម | ថវិកាចំនួន | ៥.១០០ ដុល្លារ |
| ៩-លោក **សេង វ៉ាន់** | អនុប្រធានគណៈកម្មការវត្តវេទ្យាវ័ន្ត | ថវិកាចំនួន | ៥.១០០ ដុល្លារ |
| ១០-លោក **ជួន ជឿន** | អនុប្រធានអាចារ្យវត្តឧត្តមរុក្ខារាម | ថវិកាចំនួន | ៥.០៨៧ ដុល្លារ |
| ១១-លោក **ថ្លាង ម៉ិច** | គណៈកម្មការវត្តសិរីពោធិ៍មង្គល | ថវិកាចំនួន | ៥.០៧៨ ដុល្លារ |
| ១២-លោក **ស៊ុយ អ៊ុន** | ប្រធានគណៈកម្មការវត្តកោះជុំ | ថវិកាចំនួន | ៥.០២០ ដុល្លារ |
| ១៣-ឧបាសក **វណ្ណ ហ៊ី** | អាចារ្យវត្តឧត្តមរុក្ខារាម | ថវិកាចំនួន | ៥.០២០ ដុល្លារ |
| ១៤-លោក **អ៊ឹម សែម** | គណៈកម្មការវត្តសិរីពោធិ៍មង្គល | ថវិកាចំនួន | ៥.០១០ ដុល្លារ |
| ១៥-លោក **ហ៊ឹម ហឿន** | អនុប្រធានគណៈកម្មការវត្តឧត្តមរុក្ខារាម | ថវិកាចំនួន | ៥.០០០ ដុល្លារ |
| ១៦-លោក **ដួង គៀម** | មន្ត្រីចូលនិវត្តន៍ | ថវិកាចំនួន | ៥.០០០ ដុល្លារ |
| ១៧-ឧបាសិកា **ដាក រ៉េន** | សប្បុរសជននៅខេត្តពោធិ៍សាត់ | ថវិកាចំនួន | ៥.០០០ ដុល្លារ |

**គ. មេដាយសំរិទ្ធិស្ថាបនាជាតិចំនួន ០៦ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ឧបាសិកា **មាស មុំ** | សប្បុរសជននៅខេត្តពោធិ៍សាត់ | ថវិកាចំនួន | ២.៤១៥ ដុល្លារ |
| ២-ឧបាសិកា **អ៊ឹក សុគ** | សប្បុរសជននៅខេត្តពោធិ៍សាត់ | ថវិកាចំនួន | ២.៣៨៧ ដុល្លារ |
| ៣-ឧបាសិកា **ស្រី ថ្ងៃ** | សប្បុរសជននៅខេត្តពោធិ៍សាត់ | ថវិកាចំនួន | ២.១៥០ ដុល្លារ |
| ៤-លោក **ជួន ចេង** | សមាជិកគណៈកម្មការវត្តឧត្តមរុក្ខារាម | ថវិកាចំនួន | ១.៦១០ ដុល្លារ |
| ៥-លោក **អ៊ុំ អឿន** | គណៈកម្មការវត្តសិរីពោធិ៍មង្គល | ថវិកាចំនួន | ១.២៥០ ដុល្លារ |
| ៦-លោក **លួន គន** | គណៈកម្មការវត្តសិរីពោធិ៍មង្គល | ថវិកាចំនួន | ១.២២៥ ដុល្លារ |

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៨៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ផ្តល់ជូនលោកជំទាវ **គេច ច័ន្ទសុគ័ន្ធ្រា** សប្បុរសជននៅរាជធានីភ្នំពេញ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានានៅក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តកោះជុំ** ស្ថិតនៅក្នុងឃុំក្តោតជុំ ស្រុកបាកាន ខេត្តពោធិ៍សាត់ *ចំណាយអស់ថវិកាសរុបចំនួន ១៣០.៤០០ ដុល្លារ* ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៨៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្ដល់ជូនសប្បុរសជនចំនួន ០៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ សាលាធម្មសភា ក្លោងទ្វារ កុដិ ជង់ទង់ និងសមិទ្ធផលនានាជាច្រើនទៀត នៅ **វត្តអង្គធ្លករង្សី** ស្ថិតនៅក្នុងឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ប៊ី ភន** | ព្រះចៅអធិការវត្តអង្គធ្លករង្សី | បច្ច័យចំនួន ២៥.០០០ ដុល្លារ |
| ២-លោក | **យិន អៀង** | សប្បុរសជននៅខេត្តតាកែវ | ថវិកាចំនួន ២៣.០០០ ដុល្លារ |
| ៣-លោក | **ផូ ផន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ២១.០០០ ដុល្លារ |
| ៤-អ្នកគ្រូ | **ម៉ម ណេត** | សប្បុរសជននៅខេត្តកណ្ដាល | ថវិកាចំនួន ១៩.៧៤៩ ដុល្លារ |

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៤៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំជាថ្មីនូវគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧០ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

## សម្រេច

**មាត្រា ១** : តែងតាំងមន្ត្រីរាជការ ចំនួន ៤ រូប នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដូចមានរាយនាមខាងក្រោមៈ

១- លោក ញ៉ែម ប៊ុនធឿន ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងពាក្យបណ្តឹង
២- លោក សាត ដារ៉ា ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងពាក្យបណ្តឹង
៣-លោក បាន ថេរ៉ូ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានស៊ើបអង្កេត និងអប់រំសិទ្ធិមនុស្ស
៤- លោក ជូ ហេង ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានស៊ើបអង្កេត និងអប់រំសិទ្ធិមនុស្ស

**មាត្រា ២**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩៥០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិលោក **ផុន លីវីរៈ** ពីឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៨ ទៅជាឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៩ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងតែងតាំងជាអភិបាលរង នៃគណៈអភិបាលខេត្តកោះកុង។

**មាត្រា ២ :** ក្នុងរយៈពេលមកបំពេញភារកិច្ចក្នុងមុខតំណែងថ្មីខាងលើនេះ លោក **ផុន លីវិរៈ** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ...៩៥១...អនក្រ.បក

## អនុក្រឹត្យ
### ស្តីពី
### ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈ ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ មកជាអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ចាន់ សុធា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៨ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ បន្ថែមលើមុខតំណែងបច្ចុប្បន្ន។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល :**</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៦៤៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ ~**

ត្រូវបានផ្តល់មេដាយ **ស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នាយនគរបាលជាតិ និងសប្បុរសជន ចំនួន ៣២ នាក់ នៃក្រសួងមហាផ្ទៃ មានចិត្តសប្បុរសជួយឧបត្ថម្ភថវិកាដើម្បីសាងសង់ប៉ុស្តិ៍នគរបាលរដ្ឋបាល នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប និងចូលរួមចំណែកក្នុងការការពារថែរក្សាសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដូចមានរាយនាមខាងក្រោម:

**ក- មេដាយ មាស ស្ថាបនាជាតិ**

១-នាយឧត្តមសេនីយ៍ **ខេង សុមេធ** អត្តលេខ ០៧២៧១ អគ្គស្នងការរងនគរបាលជាតិ

២-លោកវរសេនីយ៍ទោ **ស៊ីន់ ចំណាន** អត្តលេខ ០៧៩៩៥ នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

**ខ- មេដាយ ប្រាក់ ស្ថាបនាជាតិ**

១-លោកវរសេនីយ៍ត្រី **លឹម ឆាយ** អត្តលេខ ០៨២៧២ នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តកោះកុង

២-លោកអនុសេនីយ៍ឯក **សីហ៍ ខន** អត្តលេខ ០៣៩៨៨ អធិការរង នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៣-លោកអនុសេនីយ៍ឯក **ធី មូលីរ័ត្ន** អត្តលេខ ១៣៥២០ អធិការរង នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៤-លោកអនុសេនីយ៍ឯក **ចោះ ចន្ថា** អត្តលេខ ១៣៥២៣ អធិការរង នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៥-លោកអនុសេនីយ៍ទោ **គិន និស្ស័យ** អត្តលេខ ១៣៥២២ នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៦-លោកអនុសេនីយ៍ទោ **សិត់ សែ** អត្តលេខ ២២៧៧៨ នាយប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៧-លោកអនុសេនីយ៍ទោ **ញឹក សុផល** អត្តលេខ ១៥៧៣០ នាយប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៨-លោកអនុសេនីយ៍ត្រី **សាខ ពិសាល** អត្តលេខ ២៩៦០៥ នាយរងប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៩-លោក **ចៅច័ន្ទ សុរិយា** សប្បុរសជន

**គ- មេដាយ សំរិទ្ធ ស្ថាបនាជាតិ**

១-លោកវរសេនីយ៍ត្រី **ទេព ពុំសេន** អត្តលេខ ០៨០១៥ អធិការ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

២-លោកវរសេនីយ៍ត្រី **ម៉ិន គា** អត្តលេខ ០៨០៥៩ អធិការ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៣-លោកវរសេនីយ៍ត្រី **ទេព ចាន់ណា** អត្តលេខ ០៨០៦២ អធិការ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៤-លោកអនុសេនីយ៍ឯក **គិន ចំរើន** អត្តលេខ ១០៥១៣ នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៥-លោកអនុសេនីយ៍ទោ **លី សា** អត្តលេខ ២០១៧៥ អធិការរង នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៦-លោកអនុសេនីយ៍ទោ **ថាច់ ចណ្ណឌី** អត្តលេខ ២០១២៣ នាយប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៧-លោកអនុសេនីយ៍ទោ **ឡោ ឡាយ** អត្តលេខ ១៣៦២២ នាយប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៨-លោកអនុសេនីយ៍ទោ **ឈុម សំបាន** អត្តលេខ ២៩៧២២ នាយប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

៩-លោកអនុសេនីយ៍ទោ **លី ថុខផលរ៉ាត់** អត្តលេខ ២០១៣១ នាយប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

១០-លោកអនុសេនីយ៍ទោ **សុខ ម៉ីនរ៉ុង** អត្តលេខ ២០១៦១ នាយផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

១១-លោកអនុសេនីយ៍ត្រី **ស៊ុយ សេងអ៊ី** អត្តលេខ ៥៨៧៨៦ នាយប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

១២-លោកអនុសេនីយ៍ត្រី **សឿម សុំ** អត្តលេខ ២៩៨៨០ នាយរងប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

១៣-លោកអនុសេនីយ៍ត្រី **សី ស៊ិនណារ៉ា** អត្តលេខ ០៩៦៧៩ នាយរងប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

១៤-លោកអនុសេនីយ៍ត្រី **ឆាម ធឿត** អត្តលេខ ២៩៨០០ នាយរងប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

១៥-លោកអនុសេនីយ៍ត្រី **ស្ងួន សាត** អត្តលេខ ២៩៨៧២ មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

១៦-លោកព្រិន្ទបាលឯក **ប៉ម ព្រាន** អត្តលេខ ២៩៩១៦ មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

១៧-លោកព្រិន្ទបាលឯក **ធឹម រិទ្ធា** អត្តលេខ ៥៦៨៧០ មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

១៨-លោកព្រិន្ទបាលឯក **សំ ឈុន** អត្តលេខ ៦១៤៣៦ មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

១៩-លោកព្រិន្ទបាលទោ **អ៊ុម ឡៃ** អត្តលេខ ៨៥៥៨៦ នាយរងប៉ុស្តិ៍ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

២០-លោកព្រិន្ទបាលទោ **លីម សុឈុនលេខ** អត្តលេខ ៦៧៧២៩ មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

២១-លោកព្រិន្ទបាលទោ **ហៅ ហ៊ាន** អត្តលេខ ៨៥២១៨ មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា១ និងមាត្រា២*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:..៩៥៣..អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានផ្តល់គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនដល់លោក **មាស សុភក្តិ** ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តតាកែវ ដែលបានសហការល្អជាមួយស្នងការដ្ឋាននគរបាលខេត្តតាកែវ ធ្វើសកម្មភាពបង្ក្រាបនិងចាប់មុខសញ្ញាចោរលួចបេតិកភ័ណ្ឌជាតិ (ព្រះសុវណ្ណកោដ្ឋដាក់ព្រះបរមសារីរិកធាតុនិងរូបសំណាកសូន្យអំពីលោហៈធាតុពណ៌លឿងមួយចំនួន) កាលពី ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ នៅភូមិ កកោះ ឃុំ ខ្វាវ ស្រុក ទ្រាំង ខេត្ត តាកែវ បានដោយជោគជ័យ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា១ និងមាត្រា២*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៩៥៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកាល់ម៉ែត

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៣១១/២៣៤ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការប្រែក្លាយមន្ទីរពេទ្យកាល់ម៉ែត ជាគ្រឹះស្ថានសាធារណៈសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៣១១/២៨៥ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការតែងតាំងឯកឧត្តម វេជ្ជបណ្ឌិត ឈាង រ៉ា ជាអគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត
- បានឃើញអនុក្រឹត្យ លេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

### សម្រេច

**មាត្រា ១:** តែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកាល់ម៉ែត ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម វេជ្ជបណ្ឌិត | **ឈាង រ៉ា** | អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត | ជាប្រធានក្រុមប្រឹក្សាភិបាល |
| ២. លោកជំទាវ | **ឱ្យ វណ្ណឌីន** | អគ្គនាយកបច្ចេកទេសសុខាភិបាល | ជាសមាជិកស្វ័យប្រវត្តិ |
| ៣. ឯកឧត្តម | **ខឹម ទិសិដ្ឋ** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |

៤. លោក **ឈួន សំរិទ្ធ** តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៥. ឯកឧត្តម **ម៉ម់ សារិន** តំណាងសាលារាជធានីភ្នំពេញ ជាសមាជិក

៦. ឯកឧត្តម **សាផុន វឌ្ឍនៈ** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ជាសមាជិកស្ម័យប្រវត្តិ

៧. លោកសាស្ត្រាចារ្យ **ខ្និ ខ៉ាន់ដា** តំណាងមន្ត្រីរាជការ.បុគ្គលិក ជាសមាជិកស្វ័យប្រវត្តិ ។

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៩៥៥ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១ .-** តែងតាំងមន្ត្រីរាជការចំនួន ០៦ រូប ជានាយករង និងប្រធាននាយកដ្ឋាន នៃសាលាភូមិន្ទរដ្ឋបាលរបស់ក្រសួងមុខងារសាធារណៈ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក | **ទ៉ាន់ ប៉ូលុយ** | ជានាយករង មានឋានៈស្មើអគ្គនាយករង |
| ២-លោក | **ស៊ុខ ទិនធិ** | ជានាយករង មានឋានៈស្មើអគ្គនាយករង |
| ៣-លោកស្រី | **លឹម ចន្ធនី** | ជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៤-លោក | **អ៊ុខ សារ៉ាទ៉ាន់** | ជាប្រធាននាយកដ្ឋានស្រាវជ្រាវ និងទំនាក់ទំនងអន្តរជាតិ |

៥-លោក **ទេព កុសល** ជាប្រធាននាយកដ្ឋានបណ្ដុះបណ្ដាលដំបូង

៦-លោក **ស្រ៊ាង ផានិត** ជាប្រធាននាយកដ្ឋានបណ្ដុះបណ្ដាលបន្ត

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...១១៤៧...អនក្រ.តត

# អនុក្រឹត្យ

**ស្តីពី**

**ការផ្ទេរក្របខ័ណ្ឌ នាយទាហាន**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនលោកវរសេនីយ៍ឯក **នឹម ច័ន្ទតារាណា** អត្តលេខ ០២១១៦៦ ស្នងការរង ស្នងការដ្ឋានបុគ្គលិក បណ្ដុះបណ្តាល បញ្ជាការដ្ឋានអង្គរក្ស អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នទៅបម្រើការងារក្នុងក្របខ័ណ្ឌ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរក្របខ័ណ្ឌ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនឧត្តមសេនីយ៍ត្រី **ប្រាក់ សោភ័ណ្ឌ** អត្តលេខ ២៣១៥៥១ នាយករង នាយកដ្ឋានទំនាក់ទំនងសហប្រតិបត្តិការ រក្សាសន្តិភាព និងនីតិកម្ម មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាពបោសសំអាតមីន និងកាកសំណល់សង្គ្រាម បច្ចុប្បន្នទៅបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៥៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនឧត្តមសេនីយ៍ទោ **ស៊ូ ស៊ុម** អត្តលេខ ០០០៦៨៣ ជា អគ្គនាយករង អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៩៤៩ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ចំនួន ០១គ្រឿង ជូនលោក Khalid EL Harizi ប្រធានគ្រប់គ្រងកម្មវិធីប្រចាំប្រទេសកម្ពុជា របស់មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) ដែលមានស្នាដៃល្អ ក្នុងកិច្ចសម្របសម្រួលហិរញ្ញប្បទានជាមួយ IFAD និងអង្គភាពពាក់ព័ន្ធដទៃទៀត កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៣ខែ កញ្ញា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនសាខាវិទ្យាស្ថានវិទ្យាសាស្ត្រយោធា របស់ក្រសួងការពារជាតិវៀតណាម ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច នៃក្រសួងការពារជាតិកម្ពុជា កន្លងមក ។

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ២០១៤
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៦១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- យោងតាមសំណើក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ :** ប្តូរប្រភេទក្របខ័ណ្ឌតាមរយៈការប្រឡងប្រជែង របស់មន្ត្រីរាជការចំនួន ១២ រូប នៅក្រសួងសាធារណការ និងដឹកជញ្ជូន ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម នៃក្របខ័ណ្ឌមន្ត្រីបច្ចេកមធ្យម ៖

| ល.រ | គោត្តនាម និងនាម | ក្របខ័ណ្ឌចាស់ | ក្របខ័ណ្ឌថ្មី |
|---|---|---|---|
| ១ | លោកស្រី អៃ សុវត្ថារី | លេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២ | លោកស្រី ខឹម វិចិត្រ | លេខាធិការរដ្ឋបាល ថ្នាក់លេខ ៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣ | លោកស្រី ផេង សុប៉ុណ្ណា | លេខាធិការរដ្ឋបាល ថ្នាក់លេខ ១០ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤ | លោក ព្រែម វិបុល | លេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៥ | លោក សាត់ រិន | លេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៦ | លោក ឡាយ បូរិន | លេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៧ | លោកស្រី អ៊ុំ ពីឃឿន | លេខាធិការរដ្ឋបាល ថ្នាក់លេខ ១១ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |

| | | | |
|---|---|---|---|
| ៨ | លោក ខេង ប៊ុនថេង | នាយលេខាធិការរដ្ឋបាល ថ្នាក់លេខ ៣ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៩ |
| ៩ | លោក ផាង ប៉ាក់ណា | ភ្នាក់ងាររដ្ឋបាល ថ្នាក់លេខ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១០ | លោក ផយ សុធី | លេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១១ | លោក អេម ស៊ិន | នាយលេខាធិការរដ្ឋបាល ថ្នាក់លេខ ២ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨ |
| ១២ | លោកស្រី មិន សុគន្ធា | លេខាធិការរដ្ឋបាល ថ្នាក់លេខ ៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីនៃក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល ៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧៦. សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការជ្រើសរើសពលទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១** : អនុញ្ញាតឲ្យក្រសួងការពារជាតិ ជ្រើសរើសពលទាហាន ចំនួន ១០៥០ ( មួយពាន់ហាសិប )នាក់ ដើម្បីបំពេញឲ្យ ៖
- កងពលតូចថ្មើរជើងលេខ៧០ អគ្គបញ្ជាការដ្ឋាន ចំនួន ៧០០ ( ប្រាំពីររយ ) នាក់
- បញ្ជាការដ្ឋានអង្គរក្ស អគ្គបញ្ជាការដ្ឋាន ចំនួន ៣៥០ ( បីរយហាសិប ) នាក់

**ប្រការ២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ
- រាជកិច្ច

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៣៧៧.សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៥ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- បានឃើញអនុក្រឹត្យលេខ៥៧អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៩៩អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

- បានឃើញអនុក្រឹត្យលេខ២៥១ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៩៩អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដែលមានសមាសភាពដូចខាងក្រោម៖

១- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយស

| | | | |
|---|---|---|---|
| ២- ឯកឧត្តម | **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ៣- ឯកឧត្តម | **ឌី សុគន្ធ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤- ឯកឧត្តម | **ឌិត ទីណា** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | អនុប្រធាន |
| ៥- ឯកឧត្តម | **តន់ ម៉ាន់ថារ៉ា** | រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | អនុប្រធាន |
| ៦- ឯកឧត្តម | **អ៊ុក ប្រជា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- ឯកឧត្តម | **ឡេង សេង** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- ឯកឧត្តម | **គីម សុវណ្ណា** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩- ឯកឧត្តម | **រស់ សីលវ៉ា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១០- ឯកឧត្តម | **ញ៉ែម សារ៉ន** | អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១១- ឯកឧត្តម | **ទឹង ស៊ីនី** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១២- ឯកឧត្តម | **នុត ច័ន្ទសុខា** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៣- ឯកឧត្តម | **ឃួន ផុនរតនៈ** | អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤- លោកជំទាវ | **ទន់ សាអ៊ីម** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ១៥- ឯកឧត្តម | **លី ឈួង** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៦- ឯកឧត្តម | **ប៊ិន សម្បត្តិថារ័ត្ន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៧- ឯកឧត្តម | **លី ស៊ីមអ៊ាម** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៨- ឯកឧត្តម | **អ៊ុំ ផល្លី** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៩- លោកជំទាវ | **ញ៉ែម មរកត** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ២០- ឯកឧត្តម | **ម៉ា នរិទ្ធ** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| ២១- ឯកឧត្តម | **ហេង សុខណាង** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២២- ឯកឧត្តម | **គល់ ទង្គនា** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក។ |

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.......សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការកែសម្រួលការប្រើប្រាស់ប្រាក់រង្វាន់នៃចំណូលប្រមូលដោយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ៨៦២ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិង



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom, Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

ហិរញ្ញវត្ថុ ស្តីពីការប្រើប្រាស់ប្រាក់រង្វាន់នៃចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

- យោងប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្ត ដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងលិខិតលេខ ៣៤២៤ សហវ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុញ្ញាតប្រើប្រាស់ថវិការង្វាន់ នៃចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រាក់រង្វាន់១%នៃចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលត្រូវបានកំណត់តាមបញ្ញត្តិលិខិតលេខ ៣៤២៤ សហវ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួល និងកំណត់បែងចែកឡើងវិញដូចតទៅ÷

- ៦០%នៃប្រាក់រង្វាន់ សម្រាប់ឧបត្ថម្ភជីវភាពជូនមន្ត្រីរាជការគយនិងរដ្ឋាករទាំងឡាយណាដែលមកបំពេញការងារទៀងទាត់ ទៅតាមគោលការណ៍សមធម៌ ប្រកបដោយគុណភាព និងផលិតភាព។
- ១៥%នៃប្រាក់រង្វាន់ សម្រាប់ឧបត្ថម្ភមុខងារជូនមន្ត្រីរាជការគយនិងរដ្ឋាករទាំងឡាយណាដែលបំពេញមុខងារពាក់ព័ន្ធនឹងការងារដឹកនាំ ការងារកែទម្រង់ ការងារសិក្សាស្រាវជ្រាវ ការងាររៀបចំច្បាប់និងគោលនយោបាយ ការងារជំនាញចាំបាច់ ការងារចូលរួមអនុវត្តគម្រោង និងការងារផ្សេងៗទៀត ព្រមទាំងការងារផ្តល់មតិប្រឹក្សាច្បាប់ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។
- ១៥%នៃប្រាក់រង្វាន់ សម្រាប់ចំណាយក្នុងការអភិវឌ្ឍស្ថាប័ន សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការបំពាក់មធ្យោបាយប្រដេញ និងសម្ភារទូរគមនាគមន៍ តាមតម្រូវការចាំបាច់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាតាមបទបញ្ញត្តិជាធរមាន។
- ១០%នៃប្រាក់រង្វាន់ សម្រាប់លើកទឹកចិត្តដល់អង្គភាព និងមន្ត្រីគាំទ្រដទៃទៀតនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមគោលការណ៍សមធម៌ និងគុណសម្បត្តិការងារ។
- ៥%នៃប្រាក់រង្វាន់ ត្រៀមបំរុងក្នុងបេឡាសមូហភាព សម្រាប់ជាប្រាក់រង្វាន់សមិទ្ធិកម្ម និងសម្រាប់ចំណាយលើការឧបត្ថម្ភមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា និងមន្ត្រីជាប់កិច្ចសន្យាក្នុងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដែលមានជួបប្រទះគ្រោះថ្នាក់ ឈឺថ្កាត់ ឬមហន្តរាយផ្សេងៗ ព្រមទាំងការចំណាយចាំបាច់ប្រហាក់ប្រហែល តាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា។

**ប្រការ២.-**

ប្រាក់រង្វាន់៦០% សម្រាប់ឧបត្ថម្ភជីវភាព ដូចមានចែងក្នុងបញ្ញត្តិប្រការ១ នៃប្រកាសនេះ ត្រូវបានផ្តល់

ជូនមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជាប្រចាំខែ ទៅតាមមេគុណសមាមាត្រ ដូចមានចែងក្នុងបញ្ញត្តិប្រការ២ នៃប្រកាសលេខ ៨៦២ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចយោងខាងលើ។

ប្រាក់រង្វាន់១០% សម្រាប់ឧបត្ថម្ភមុខងារ ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ត្រូវបានផ្តល់ជូនមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជាប្រចាំខែ ទៅតាមមេគុណសមាមាត្រ ដូចមានចែងក្នុងបញ្ញត្តិប្រការ២ នៃប្រកាសលេខ ៨៦២ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចយោងខាងលើ។ ក្នុងករណីមានជំនាញពិសេសចាំបាច់ ដែលតម្រូវឱ្យមានការផ្តល់ប្រាក់ឧបត្ថម្ភមុខងារខ្ពស់ គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត អាចពិនិត្យនិងសម្រេចលើសំណើផ្តល់តាមមេគុណសមាមាត្រណាមួយ ក្នុងចំណោមមេគុណសមាមាត្រដែលបានកំណត់ខាងលើ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវកសាងបញ្ជីឈ្មោះមន្ត្រីដែលត្រូវទទួលប្រាក់ឧបត្ថម្ភមុខងារសម្រាប់មួយត្រីមាសម្តងឱ្យបានទៀងទាត់ ដើម្បីជាមូលដ្ឋានក្នុងការបែងចែកប្រាក់រង្វាន់នេះ។

**ប្រការ៣.-**

យន្តការ នីតិវិធី និងការត្រួតពិនិត្យការផ្តល់ការលើកទឹកចិត្ត ត្រូវអនុវត្តតាមបញ្ញត្តិជំពូក៣ នៃប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចយោងខាងលើ។

**ប្រការ៤.-**

បញ្ញត្តិប្រការ៧ នៃប្រកាសលេខ ៨៦២ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រើប្រាស់ប្រាក់រង្វាន់នៃចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**<u>កន្លែងទទួល</u>** ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា "ដើម្បីជូនជ្រាប"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ...៩៦០.....សហវ.ប្រក

**ប្រកាស**

**ស្តីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យ**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានពន្ធដារ

**សម្រេច**

**ប្រការ១.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២.- គោលបំណង**

ប្រកាសនេះ មានគោលបំណងដូចខាងក្រោម÷

- រៀបចំរចនាសម្ព័ន្ធរបស់ការិយាល័យក្រោមឱវាទនាយកដ្ឋានត្រួតពិនិត្យនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំមុខងារ និងភារកិច្ចរបស់ការិយាល័យក្រោមឱវាទនាយកដ្ឋានត្រួតពិនិត្យនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារប្រមូលព័ត៌មានអ្នកជាប់ពន្ធ សវនកម្មផ្ទៃក្នុង ស៊ើបអង្កេតផ្ទៃក្នុង និងស៊ើបអង្កេតបទល្មើសពន្ធដារ។

**ប្រការ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ការិយាល័យក្រោមឱវាទនាយកដ្ឋានត្រួតពិនិត្យនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤.- ភារកិច្ចរបស់នាយកដ្ឋានត្រួតពិនិត្យ**

នាយកដ្ឋានត្រួតពិនិត្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារត្រួតពិនិត្យ ដោយមានភារកិច្ច ដូចតទៅ÷

- រៀបចំ និងអនុវត្ត គោលការណ៍ណែនាំ ផែនការ នីតិវិធី និងស្តង់ដារពាក់ព័ន្ធការងារប្រមូលព័ត៌មានអ្នកជាប់ពន្ធ សវនកម្មផ្ទៃក្នុង ស៊ើបអង្កេតផ្ទៃក្នុង និងស៊ើបអង្កេតបទល្មើសពន្ធដារ
- រៀបចំ និងអនុវត្ត កម្មវិធីបណ្តុះបណ្តាលពាក់ព័ន្ធការអភិវឌ្ឍការងារប្រមូលព័ត៌មានអ្នកជាប់ពន្ធ សវនកម្មផ្ទៃក្នុង ស៊ើបអង្កេតផ្ទៃក្នុង និងស៊ើបអង្កេតបទល្មើសពន្ធដារ
- វាយតម្លៃ អំពីប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង របស់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ សំដៅពង្រឹងអភិបាលកិច្ចល្អ
- សម្របសម្រួល និងសហការជាមួយ អង្គភាពក្រោមឱវាទ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការងារស៊ើបអង្កេតបទល្មើសពន្ធដារ
- ធ្វើរបាយការណ៍ពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ
- អនុវត្តភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារប្រគល់ជូន។

**ប្រការ៥.- ការដឹកនាំ**

នាយកដ្ឋានត្រួតពិនិត្យ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការ។

**ប្រការ៦.- រចនាសម្ព័ន្ធ**

នាយកដ្ឋានត្រួតពិនិត្យ មានការិយាល័យចំណុះចំនួន ០៦ គឺ÷

១- ការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ

២- ការិយាល័យប្រមូលព័ត៌មានអ្នកជាប់ពន្ធ

៣- ការិយាល័យសវនកម្មផ្ទៃក្នុងទី១

៤- ការិយាល័យសវនកម្មផ្ទៃក្នុងទី២

៥- ការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារទី១

៦- ការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារទី២។

**ប្រការ៧._ តួនាទី និងភារកិច្ចរបស់ការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ**

ការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំ និងអនុវត្តគោលនយោបាយ និងនីតិវិធី ដើម្បីថែរក្សាសំណុំឯកសារមន្ត្រីពន្ធដារនិងតាមពិនិត្យការងារ លើកសរសើរ ដាក់ពិន័យ និងគាំពារមន្ត្រីពន្ធដារ និងគ្រប់គ្រងបុគ្គលិកជាប់កិច្ចសន្យា
- រៀបចំប្រាក់បៀវត្ស និងក្របខ័ណ្ឌប្រាក់កម្រៃ និងរបបឧបត្ថម្ភបន្ទុកគ្រួសារ គោលនយោបាយធានារ៉ាប់រងសង្គម របបសម្រាកលំហែ និងស្នើសុំដំឡើងកាំប្រាក់បៀវត្សប្រចាំឆ្នាំ គ្រប់គ្រងស្ថិតិ និងឥណទាន បៀវត្សមន្ត្រីប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនមន្ត្រីពន្ធដារ
- រៀបចំសំណើទៅប្រធាននាយកដ្ឋាន ដើម្បីដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ពិនិត្យ និងសម្រេចស្នើសុំការតែងតាំងផ្លាស់ប្តូរ លុបឈ្មោះចេញពីក្របខ័ណ្ឌ សុំឈប់ពីការងារ និងដាក់ឱ្យចូលនិវត្តន៍របស់មន្ត្រីពន្ធដារ
- រៀបចំផែនការ និងលើកសំណើបណ្តុះបណ្តាល ឬអភិវឌ្ឍសមត្ថភាព សម្រាប់មន្ត្រីពន្ធដារ
- គ្រប់គ្រង និងសម្របសម្រួលការងាររដ្ឋបាលរបស់នាយកដ្ឋាន
- បង្កើត និងគ្រប់គ្រងប្រព័ន្ធបែងចែកនិងប្រគល់ឯកសារ លិខិតស្នាមទាំងអស់ ដែលចេញនិងចូលនាយកដ្ឋាន
- រៀបចំ គ្រប់គ្រង ថែរក្សា ការពារ និងស្នើជួសជុល សម្ភារៈបរិក្ខារការិយាល័យ របស់នាយកដ្ឋាន
- ស្នើសុំ និងបើកផ្តល់ថវិកាសម្រាប់ផ្គត់ផ្គង់រាល់មធ្យោបាយ និងសម្ភារៈចាំបាច់សម្រាប់បំពេញការងារដល់គ្រប់ការិយាល័យរបស់នាយកដ្ឋាន
- រៀបចំគម្រោងចំណាយ និងសម្ភារៈ សម្រាប់ដំណើរការការងាររបស់នាយកដ្ឋាន
- កត់ត្រា និងរក្សាទុកបញ្ជីគណនេយ្យ និងលិខិតយុត្តិការផ្សេងៗ ដែលទាក់ទងនឹងចំណាយរបស់នាយកដ្ឋាន
- អនុវត្តរាល់ការងារនិងភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ៨._ ភារកិច្ចរបស់ការិយាល័យប្រមូលព័ត៌មានអ្នកជាប់ពន្ធ**

ការិយាល័យប្រមូលព័ត៌មានអ្នកជាប់ពន្ធ មានភារកិច្ច ដូចតទៅ÷

- រៀបចំនិងគ្រប់គ្រងឯកសារ លិខិតបទដ្ឋាន និងនីតិវិធីទាក់ទងទៅនឹងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ
- ស្រាវជ្រាវ និងប្រមូលព័ត៌មានអ្នកជាប់ពន្ធពីក្រសួង ស្ថាប័ន សហគ្រាស និងតតិយជនដែលពាក់ព័ន្ធ ដើម្បីបង្កើតតារាងទិន្នន័យផ្ដុំព័ត៌មានសម្រាប់គាំទ្រការងារសវនកម្ម និងការងារស៊ើបអង្កេតបទល្មើសពន្ធដារ
- ប្រមូលព័ត៌មានសហគ្រាសដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ននានា ជូនទៅនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងសាខាពន្ធដារខេត្ត-ខណ្ឌ សម្រាប់ផ្ទៀងផ្ទាត់ការចុះបញ្ជីពន្ធដារ

- ត្រួតពិនិត្យប្រសិទ្ធភាពនៃការប្រើប្រាស់ទិន្នន័យស្ថិតិព័ត៌មាន ដែលបញ្ជូនទៅអង្គភាពពន្ធដារ
- អនុវត្តរាល់ការងារនិងភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ៩._ ភារកិច្ចរបស់ការិយាល័យសវនកម្មផ្ទៃក្នុង**

ការិយាល័យសវនកម្មផ្ទៃក្នុងទី១ និងការិយាល័យសវនកម្មផ្ទៃក្នុងទី២ មានភារកិច្ច ដូចតទៅ÷

- ចូលរួមរៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំដោយប្រើប្រាស់វិធីសាស្ត្រផ្អែកលើកម្រិតហានិភ័យ ដើម្បីកំណត់អាទិភាពសវនកម្មផ្ទៃក្នុងលើផ្នែកដែលមានហានិភ័យខ្ពស់ និងលើបញ្ហាប្រឈមសំខាន់ៗ របស់អគ្គនាយកដ្ឋានពន្ធដារ
- ធ្វើសវនកម្ម លើការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារជាធរមាន
- ធ្វើសវនកម្ម លើការអនុវត្តការងារគ្រប់គ្រងប្រមូលពន្ធតាមរបបម៉ៅការដែលរួមមាន ការអនុវត្តនីតិវិធីនិងបែបបទនៃការផ្តល់សេវា ការចុះបញ្ជី ការកំណត់ពន្ធ ការប្រមូលពន្ធ ការប្រមូលបំណុលពន្ធ ការបង់ពន្ធចូលរតនាគារជាតិ និងធនាគារ រួមទាំងបញ្ជីពន្ធ ការប្រើប្រាស់ឯកសារបោះពុម្ព និងកិច្ចបញ្ជិកាគណនេយ្យ
- ធ្វើសវនកម្ម លើការអនុវត្តការងារគ្រប់គ្រងប្រមូលពន្ធតាមរបបស្វ័យប្រកាស ដែលរួមមានការអនុវត្តនីតិវិធីនិងបែបបទនៃការផ្តល់សេវា ការចុះបញ្ជី ការដាក់លិខិតប្រកាស ការធ្វើសវនកម្មគ្រប់ប្រភេទ ការប្រមូលបំណុលពន្ធ និងនីតិវិធីដោះស្រាយពាក្យបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ
- ធ្វើសវនកម្ម លើប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងភាពគ្រប់ជ្រុងជ្រោយរបស់អគ្គនាយកដ្ឋានពន្ធដារ និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដែលមានជាអាទិ៍ ការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការគ្រប់គ្រងមន្ត្រីពន្ធដារ ភាពសន្សំសំចៃនៃការប្រើប្រាស់ធនធានរដ្ឋ ភាពត្រឹមត្រូវនៃព័ត៌មាននិងស្ថិតិ អនុលោមតាមច្បាប់ បទដ្ឋានគតិយុត្តជាធរមាន និងប្រសិទ្ធភាព នៃប្រតិបត្តិការតាមគោលការណ៍អភិបាលកិច្ចល្អ
- អនុវត្តសវនកម្មផ្ទៃក្នុងដោយឯករាជ្យ និងគ្មានការរារាំង ស្របតាមស្តង់ដារ និងគោរពតាមក្រមសីលធម៌វិជ្ជាជីវៈនៃសវនកម្មផ្ទៃក្នុង
- វាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារសំដៅពង្រឹងអភិបាលកិច្ចល្អ
- ធ្វើសវនកម្ម លើការធ្វើជំរឿនអ្នកធ្វើអាជីវកម្ម ដោយសាខាពន្ធដារខេត្ត-ខណ្ឌ
- ធ្វើសវនកម្ម លើការផ្ទេរអ្នកជាប់ពន្ធតាមរបបម៉ៅការដែលមានផលរបរត្រូវជាប់ពន្ធតាមរបបស្វ័យប្រកាសនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ
- អប់រំណែនាំអំពីសុចរិតភាពជូនមន្ត្រីពន្ធដារ និងមន្ត្រីជាប់កិច្ចសន្យាដែលបម្រើការងារនៅតាមអង្គភាពចំណុះអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទប់ស្កាត់ការរំលោភបំពានក្រមសីលធម៌វិជ្ជាជីវៈ
- ទទួលពាក្យបណ្តឹង វិភាគ ស៊ើបអង្កេត និងស្រាវជ្រាវ ដើម្បីលើកយោបល់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យនិងសម្រេចអនុវត្តវិធានការរដ្ឋបាល ចំពោះមន្ត្រីពន្ធដារ និងបុគ្គលិកជាប់កិច្ចសន្យាដែលរំលោភបំពាន

ក្រមសីលធម៌វិជ្ជាជីវៈ

- តាមដាន និងរក្សាទុកសំណុំរឿងនៃពាក្យបណ្ដឹង
- ផ្ដល់នូវរបាយការណ៍លទ្ធផល នៃការធ្វើសវនកម្មផ្ទៃក្នុង និងលើកសំណើដំណោះស្រាយ ជូនប្រធាននាយកដ្ឋាន ដើម្បីដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យនិងសម្រេច
- ធ្វើរបាយការណ៍សកម្មភាពរបស់ការិយាល័យសវនកម្មផ្ទៃក្នុងប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនប្រធាននាយកដ្ឋាន
- អនុវត្តរាល់ការងារនិងភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ១០.- ភារកិច្ចរបស់ការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារ**

ការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារទី១ និងការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារទី២ មានភារកិច្ចដូចតទៅ÷

- ចូលរួមរៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពស៊ើបអង្កេតបទល្មើសពន្ធដារប្រចាំឆ្នាំ ដោយប្រើប្រាស់វិធីសាស្ត្រផ្អែកលើកម្រិតហានិភ័យខ្ពស់ ដើម្បីកំណត់អាទិភាពស៊ើបអង្កេតបទល្មើសពន្ធដារ
- រៀបចំវិធីសាស្ត្រប្រតិបត្តិការ ត្រួតពិនិត្យ និងវិធីសាស្ត្រស៊ើបអង្កេតបទល្មើសពន្ធដារ
- កំណត់លក្ខណៈវិនិច្ឆ័យដើម្បីផ្ទេរអ្នកជាប់ពន្ធដែលស្ថិតក្នុងការធ្វើសវនកម្មគ្រប់ប្រភេទ ដែលមានហានិភ័យខ្ពស់នៅនាយកដ្ឋានសវនកម្មសហគ្រាស នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងសាខាពន្ធដារខេត្ត-ខណ្ឌ មកការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារ
- ជ្រើសរើសអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់ ដើម្បីធ្វើការស៊ើបអង្កេតបទល្មើសពន្ធដារ
- អនុវត្តការស៊ើបអង្កេតបទល្មើសពន្ធដារ
- រៀបចំរបាយការណ៍លទ្ធផលនៃការស៊ើបអង្កេតបទល្មើសពន្ធដារដែលបានរកឃើញ និងលើកសំណើដំណោះស្រាយ ជូនប្រធាននាយកដ្ឋាន ដើម្បីដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារពិនិត្យនិងសម្រេច
- ផ្ដល់ព័ត៌មាននៃការស៊ើបអង្កេតបទល្មើសពន្ធដារជាប្រចាំ ដើម្បីតាមដានវឌ្ឍនភាពនិងលទ្ធផលនៃការស៊ើបអង្កេតបទល្មើសពន្ធដារ
- ពិនិត្យនិងសិក្សាលើមតិចូលរួមកែលម្អ ដើម្បីធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រ និងការគ្រប់គ្រងការស៊ើបអង្កេតបទល្មើសពន្ធដារ
- ធ្វើរបាយការណ៍សកម្មភាពការស៊ើបអង្កេតបទល្មើសពន្ធដារប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនប្រធាននាយកដ្ឋាន
- គ្រប់គ្រងការផ្លាស់ប្ដូរមន្ត្រីស៊ើបអង្កេតបទល្មើសពន្ធដារតាមវិស័យ ដើម្បីបង្កើននូវកម្រិតចំណេះដឹង និងជំនាញពន្ធដារ
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**ប្រការ១១.- កិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ**

ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់នាយកដ្ឋាន ឬអង្គភាពជំនាញដទៃទៀត ប្រធាននាយកដ្ឋានត្រួតពិនិត្យ ត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធទាំងនោះ ដើម្បីសុំគោលការណ៍ពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដាររួមគ្នាដោះស្រាយ។

**ប្រការ១២.- អវសានប្បញ្ញត្តិ**

ប្រកាសលេខ ៩៣៥ សហវ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យ នៃអគ្គនាយកដ្ឋានពន្ធដារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយក នៃអគ្គនាយកដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨-០១៤-២៣១ ប្រ.ក

# ប្រកាស
## ស្តីពី
## រូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី ក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ ធនាគារជាតិនៃកម្ពុជា

*******

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣៣៧ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខ ធ៨.៩៩.១២៤ ប្រក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខ ធ៨.៩៩.១២៣ ប្រក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខ ធ៨.៩៨.៣៨៥ ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- បានឃើញប្រកាសលេខ ធ៨.០១០.១៩៤ ប្រក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៤

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងរៀបចំរូបសញ្ញាធនាគារជាតិនៃកម្ពុជា សញ្ញាស័ក្តិ និងឯកសណ្ឋានសម្រាប់សម្គាល់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា។

សញ្ញាស័ក្តិ និងឯកសណ្ឋានសម្រាប់សម្គាល់ទេសាភិបាល និងទេសាភិបាលរងធនាគារជាតិនៃកម្ពុជា មានកំណត់នៅក្នុងព្រះរាជក្រឹត្យដោយឡែក។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅលើកកម្ពស់សេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់មន្ត្រីធនាគារជាតិនៃកម្ពុជានៅក្នុងការងារនិងសង្គម ក្នុងពេលបំពេញការងារជូនធនាគារជាតិនៃកម្ពុជា និងប្រទេសជាតិមាតុភូមិ។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីជាន់ខ្ពស់ និងមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជានិងអង្គភាពក្រោមឱវាទ សម្រាប់ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ។

## ជំពូកទី ២
## រូបសញ្ញាធនាគារជាតិនៃកម្ពុជា

**ប្រការ ៤.-**

រូបសញ្ញាធនាគារជាតិនៃកម្ពុជាមានសណ្ឋានដូចខាងក្រោម៖

- មានរាងពងក្រពើ
- មានអក្សរ រ វះពោះ «រ» ពណ៌ប្រាក់ស្ថិតនៅចំកណ្តាលផ្ទៃពណ៌ស
- នៅព័ទ្ធសងខាងអក្សរ «រ» មានកួរស្រូវពណ៌មាស៣(បី)ម្ខាង ចងភ្ជួចនៅបាតខាងក្រោម មានរាងជាផ្កាឈូកដោយលេចចេញនូវគល់ស្រូវខ្វែងគ្នា២(ពីរ) ហើយមានរំលេចដោយគ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់រាយគ្នាជាកង់ៗ ពីក្រោមទៅលើចំនួន៧(ប្រាំពីរ)កង់ ជារាងស្នែងក្របី និងមានចុងស្លឹកម្ខាង៤(បួន)សន្លឹកខិតជិតគ្នា។

រូបសញ្ញាធនាគារជាតិនៃកម្ពុជានេះត្រូវបានប្រើសម្រាប់ដាក់នៅលើស័ក្តិស្មា និងស័ក្តិចុងកអាវ នៃមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់និងក្របខ័ណ្ឌមន្ត្រីក្រមការ និងដាក់នៅលើស័ក្តិខ្ទាស់លើអាវបុរស ឬលើក្រមាពាក់នារី ដែលជាមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ។

រូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានរូបភាពដូចក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

## ជំពូកទី ៣
## សញ្ញាស័ក្តិ

### ប្រការ ៥.- សម្រាប់ក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់

សញ្ញាស័ក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ត្រូវបានកំណត់ដូចតទៅ៖

**១- សម្រាប់ឋានន្តរស័ក្តិឧត្តមមន្ត្រី**

**ក- អំពីស័ក្តិស្មា**

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅ៖

ក១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាគុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស ១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានត្របក ៣(បី)

ក២: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស ១(មួយ)

ក៣: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌មាស១(មួយ)គ្រាប់

ក៤: នៅជុំវិញរូបនៃចំណុច ក១-ក២-ក៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតពួរវេញពណ៌មាស ៣(បី)ខ្សែនៅតាមជរជាយជុំវិញស័ក្តិ សម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី។

**ខ- អំពីស័ក្តិចុងកអាវ**

ស័ក្តិចុងកអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស១(មួយ) នៅខាងដើម

ខ២: មានរូបភាពក្បាច់ភ្ញីវល្លិ៍ពណ៌មាស១(មួយ)មែក មាន៤(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ៣: មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានត្របក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

ខ៤: នៅជុំវិញរូបភាពនៃចំណុច ខ១-ខ២-ខ៣ មានរូបភាពកញ្ចុំ គ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជរជាយ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតព្រួរវេញ ពណ៌មាស ៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី។

**គ- អំពីស័ក្តិចុងដៃអាវ**

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅៈ

គ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស ១(មួយ)មែកយ៉ាងវែង រត់តាមបណ្តោយផ្ទៃស័ក្តិ មាន៩(ប្រាំបួន)ថ្លែ ផ្ការីក ៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីវល្លិ៍ជាច្រើន និងមានរូបផ្កាឈូកពណ៌មាស ១(មួយ)ទង មានត្របក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

គ២: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីវល្លិ៍ មានព្រួរវេញពណ៌មាស១(មួយ) ឆ្នូត ព័ទ្ធជុំវិញក្បាច់ភ្ញីវល្លិ៍ និងមានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី) គ្រាប់ដាក់រាយគ្នាជាជួរអមព្រួរវេញ ជាលម្អជរជាយ

គ៣: នៅចុងខាងក្រៅបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្នូតព្រួរវេញ ពណ៌មាស ៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ឋានន្តរស័ក្តិឧត្តមមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ឃ- អំពីស័ក្តិខ្ទាស់លើអាវ**

ស័ក្តិខ្ទាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅៈ

ឃ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌មាស១(មួយ)។ នៅផ្នែកខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌មាស "ធនាគារជាតិ នៃ កម្ពុជា"

ឃ២: មានរូបកញ្ចុំគ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ រាងកោងជាទម្រង់ស្នែងក្របីទ្រូរូបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ៣: នៅផ្នែកខាងក្រោមបង្អស់មានខ្សែព្រួរវេញពណ៌មាសព័ទ្ធអម ៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី។

ស័ក្តិខ្ទាស់លើអាវនេះ ប្រើសម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្ទាស់លើក្រមាពាក់នានារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្ទាស់លើអាវ និងលើក្រមាពាក់សម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ឋានន្តរស័ក្តិឧត្តមមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

## ២- សម្រាប់ឋានន្តរស័ក្តិវរៈមន្ត្រី

### ក- អំពីស័ក្តិស្មា

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅ៖

ក១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាគុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស ១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានត្របក៣(បី)

ក២: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌មាស ១(មួយ)

ក៣: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌មាស១(មួយ)គ្រាប់

ក៤: នៅជុំវិញរូបនៃចំណុច ក១-ក២-ក៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតពួរវេញពណ៌មាស២(ពីរ)ខ្សែនៅតាមជរជាយជុំវិញស័ក្តិ សម្រាប់សម្គាល់ឋានន្តរស័ក្តិវរៈមន្ត្រី។

### ខ- អំពីស័ក្តិចុងករអាវ

ស័ក្តិចុងករអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស១ (មួយ) នៅខាងដើម

ខ២: មានរូបភាពក្បាច់ភ្ញីវល្លិ៍ពណ៌មាស១(មួយ)មែក មាន៤(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ៣: មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានត្របក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

ខ៤: នៅជុំវិញរូបភាពនៃចំណុច ខ១-ខ២-ខ៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជរជាយ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតពួរវេញ ពណ៌មាស ២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិវរៈមន្ត្រី។

### គ- អំពីស័ក្តិចុងដៃអាវ

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

គ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាគុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស១(មួយ)មែកយ៉ាងវែង រត់តាមបណ្តោយផ្ទៃស័ក្តិ មាន៩(ប្រាំបួន)ផ្លែ ផ្ការីក៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីវល្លិ៍ជាច្រើន និងមានរូបផ្កាឈូកពណ៌មាស១(មួយ)ទង មានត្របក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

គ២: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីវល្លិ៍ មានព្ធរវេញពណ៌មាស១(មួយ) ឆ្នូតព័ទ្ធជុំវិញក្បាច់ភ្ញីវល្លិ៍ និងមានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី) គ្រាប់ដាក់រាយគ្នាជាជួរអមព្ធរវេញ ជាលម្អជរជាយ

គ៣: នៅចុងខាងក្រៅបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្នូតព្ធរវេញពណ៌មាស២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិវរៈមន្ត្រី។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ឋានន្តរស័ក្តិវរៈមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

### ឃ- អំពីស័ក្តិខ្ទាស់លើអាវ

ស័ក្តិខ្ទាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ឃ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌មាស ១(មួយ)។ នៅខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌មាស "ធនាគារជាតិ នៃ កម្ពុជា"

ឃ២: មានរូបកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី)គ្រាប់ដាក់រាយគ្នាជាជួររាងកោងជាទម្រង់ស្នែងក្របីទ្រូរូបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ៣: នៅផ្នែកខាងក្រោមបង្អស់មានខ្សែព្ធរវេញពណ៌មាសព័ទ្ធអម២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិវរៈមន្ត្រី។

ស័ក្តិខ្ទាស់លើអាវនេះ ប្រើសម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្ទាស់លើក្រមាពាក់នារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្ទាស់លើអាវ និងលើក្រមាពាក់សម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ឋានន្តរស័ក្តិវរៈមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

## ៣- សម្រាប់ឋានន្តរស័ក្តិអនុមន្ត្រី

### ក- អំពីស័ក្តិស្មា

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅ៖

ក១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស ១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានត្របក ៣(បី)

ក២: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស ១(មួយ)

ក៣: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌មាស១(មួយ)គ្រាប់

ក៤: នៅជុំវិញរូបនៃចំណុច ក១-ក២-ក៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតពួរវេញពណ៌មាស ១(មួយ)ខ្សែនៅតាមជរជាយជុំវិញស័ក្តិ សម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រី។

**ខ- អំពីស័ក្តិចុងកអាវ**

ស័ក្តិចុងកអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស១ (មួយ) នៅខាងដើម

ខ២: មានរូបភាពក្បាច់ភ្ញីវល្លិ៍ពណ៌មាស១(មួយ)មែក មាន៤(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ៣: មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានត្របក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

ខ៤: នៅជុំវិញរូបភាពនៃចំណុច ខ១-ខ២-ខ៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជរជាយ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតពួរវេញ ពណ៌មាស ១(មួយ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រី។

**គ- អំពីស័ក្តិចុងដៃអាវ**

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

គ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស១(មួយ)មែកយ៉ាងវែង រត់តាមបណ្តោយផ្ទៃស័ក្តិ មាន៩(ប្រាំបួន)ផ្លែ ផ្ការីក៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីវល្លិ៍ជាច្រើន និងមានរូបផ្កាឈូកពណ៌មាស១(មួយ)ទង មានត្របក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

គ២: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីវល្លិ៍ មានពួរវេញពណ៌មាស១(មួយ)ឆ្នូត ព័ទ្ធជុំវិញក្បាច់ភ្ញីវល្លិ៍ និងមានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរអមពួរវេញ ជាលម្អជរជាយ

គ៣: នៅចុងខាងក្រៅបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្នូតពួរវេញពណ៌មាស ១(មួយ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រី។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ឋានន្តរស័ក្តិអនុមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

**ឃ- អំពីស័ក្តិខ្នាស់លើអាវ**

ស័ក្តិខ្នាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ឃ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌មាស១(មួយ)។ នៅខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌មាស "ធនាគារជាតិ នៃ កម្ពុជា"

ឃ₂: មានរូបកញ្ចុំគ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ រាងកោង ជាទម្រង់ស្នែងក្របីទ្រូរូបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ₃: នៅផ្នែកខាងក្រោមបង្អស់មានខ្សែពួរវេញពណ៌មាសព័ទ្ធអម១(មួយ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រី។

ស័ក្តិខ្វាស់លើអាវនេះ ប្រើសម្រាប់ខ្វាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្វាស់លើក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្វាស់លើអាវ និងលើក្រមាពានាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ឋានន្តរស័ក្តិអនុមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

## ប្រការ ៦.- សម្រាប់ក្របខ័ណ្ឌមន្ត្រីក្រមការ

សញ្ញាស័ក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានកំណត់ដូចតទៅ៖

### ១- សម្រាប់ឋានន្តរស័ក្តិនាយក្រមការ

#### ក- អំពីស័ក្តិស្មា

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅ៖

ក₁: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់ ១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានត្របក៣(បី)

ក₂: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់ ១(មួយ)

ក₃: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌ប្រាក់១(មួយ)គ្រាប់

ក₄: នៅជុំវិញរូបនៃចំណុច ក₁-ក₂-ក₃ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតពួរវេញពណ៌ប្រាក់ ៣(បី)ខ្សែនៅតាមជរជាយជុំវិញស័ក្តិ សម្រាប់សម្គាល់ឋានន្តរស័ក្តិនាយក្រមការ។

#### ខ- អំពីស័ក្តិចុងកអាវ

ស័ក្តិចុងកអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ₁: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់១(មួយ) នៅខាងដើម

ខ₂: មានរូបភាពក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់១(មួយ)មែក មាន៤(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ₃: មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានត្របក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

ខ៤: នៅជុំវិញរូបភាពនៃចំណុច ខ១-ខ២-ខ៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជរជាយ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតពួរវេញ ពណ៌ប្រាក់ ៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិនាយក្រមការ។

## គ- អំពីស័ក្តិចុងដៃអាវ

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅៈ

គ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាគុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់ ១(មួយ)មែកយ៉ាងវែង រត់តាមបណ្តោយផ្ទៃស័ក្តិ មាន៤(ប្រាំបួន)ផ្លែ ផ្ការីក ៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីវល្លិ៍ជាច្រើន និងមានរូបផ្កាឈូកពណ៌ប្រាក់ ១(មួយ)ទង មានត្របក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

គ២: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីវល្លិ៍ មានពួរវេញពណ៌ប្រាក់១(មួយ) ឆ្នូតព័ទ្ធជុំវិញក្បាច់ភ្ញីវល្លិ៍ និងមានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី) គ្រាប់ដាក់រាយគ្នាជាជួរអមពួរវេញ ជាលម្អជរជាយ

គ៣: នៅចុងខាងក្រៅបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្នូតពួរវេញ ពណ៌ប្រាក់ ៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិនាយក្រមការ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិនាយក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសនេះ។

## ឃ- អំពីស័ក្តិខ្ទាស់លើអាវ

ស័ក្តិខ្ទាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅៈ

ឃ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌ប្រាក់១(មួយ)។ នៅផ្នែកខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌ប្រាក់ "ធនាគារជាតិ នៃ កម្ពុជា"

ឃ២: មានរូបកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ រាងកោងជាទម្រង់ស្នែងក្របីទ្ររូបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ៣: នៅផ្នែកខាងក្រោមបង្អស់ មានខ្សែពួរវេញពណ៌ប្រាក់ព័ទ្ធអម៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិនាយក្រមការ។

ស័ក្តិខ្ទាស់លើអាវនេះ ប្រើសម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្ទាស់លើក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្ទាស់លើអាវនិងលើក្រមាពានាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិនាយក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី៩ នៃប្រកាសនេះ។

## ២- សម្រាប់ឋានន្តរស័ក្តិក្រមការដើមខ្សែ

### ក- អំពីស័ក្តិស្មា

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅ៖

ក₁: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាគុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់ ១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានត្របក៣(បី)

ក₂: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់ ១(មួយ)

ក₃: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌ប្រាក់១(មួយ)គ្រាប់

ក₄: នៅជុំវិញរូបនៃចំណុច ក₁-ក₂-ក₃មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតពួរវេញពណ៌ប្រាក់ ២(ពីរ)ខ្សែនៅតាមជរជាយជុំវិញស័ក្តិ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការដើមខ្សែ។

### ខ- អំពីស័ក្តិចុងកអាវ

ស័ក្តិចុងកអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ₁: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់១(មួយ) នៅខាងដើម

ខ₂: មានរូបភាពក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់១(មួយ)មែក មាន៤(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ₃: មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានត្របក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

ខ₄: នៅជុំវិញរូបភាពនៃចំណុច ខ₁-ខ₂-ខ₃ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជរជាយ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតពួរវេញ ពណ៌ប្រាក់ ២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការដើមខ្សែ។

### គ- អំពីស័ក្តិចុងដៃអាវ

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

គ₁: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាគុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់១(មួយ)មែកយ៉ាងវែង រត់តាមបណ្តោយផ្ទៃស័ក្តិ មាន៩(ប្រាំបួន)ផ្លែ ផ្ការីក៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីវល្លិ៍ជាច្រើន និងមានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង មានត្របក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

គ₂: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីវល្លិ៍ មានពួរវេញពណ៌ប្រាក់១(មួយ) ឆ្នូតព័ទ្ធជុំវិញក្បាច់ភ្ញីវល្លិ៍ និងមានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី) គ្រាប់ដាក់រាយគ្នាជាជួរអមពួរវេញ ជាលម្អជរជាយ

គ₃: នៅចុងខាងក្រៅបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្នូតពួរវេញពណ៌ប្រាក់ ២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការដើមខ្សែ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិក្រមការដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី៧ នៃប្រកាសនេះ។

### ឃ- អំពីស័ក្តិខ្ទាស់លើអាវ

ស័ក្តិខ្ទាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅៈ

ឃ₁: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌ប្រាក់១(មួយ)។ នៅខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌ប្រាក់ "ធនាគារជាតិ នៃ កម្ពុជា"

ឃ₂: មានរូបកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ រាងកោងជាទម្រង់ស្នែងក្របីទ្រូរូបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ₃: នៅផ្នែកខាងក្រោមបង្អស់ មានខ្សែពួរវេញពណ៌ប្រាក់ព័ទ្ធអម២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការដើមខ្សែ។

ស័ក្តិខ្ទាស់លើអាវនេះ ប្រើសម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្ទាស់លើក្រមាពាក់នារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្ទាស់លើអាវនិងលើក្រមាពាក់សម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិក្រមការដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី៩ នៃប្រកាសនេះ។

## ៣- សម្រាប់ឋានន្តរស័ក្តិក្រមការ

### ក- អំពីស័ក្តិស្មា

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅៈ

ក₁: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានត្របក៣(បី)

ក₂: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់ ១(មួយ)

ក₃: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌ប្រាក់១(មួយ)គ្រាប់

ក៤: នៅជុំវិញរូបនៃចំណុច ក១-ក២-ក៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតពួរវេញពណ៌ប្រាក់ ១(មួយ)ខ្សែនៅតាមជរជាយជុំវិញស័ក្តិសម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការ។

**ខ- អំពីស័ក្តិចុងកអាវ**

ស័ក្តិចុងកអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់១(មួយ) នៅខាងដើម

ខ២: មានរូបភាពក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់១(មួយ)មែក មាន៥(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ៣: មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានត្របក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

ខ៤: នៅជុំវិញរូបភាពនៃចំណុច ខ១-ខ២-ខ៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជរជាយ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតពួរវេញពណ៌ប្រាក់ ១(មួយ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការ។

**គ- អំពីស័ក្តិចុងដៃអាវ**

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

គ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់១(មួយ)មែកយ៉ាងវែង រត់តាមបណ្តោយផ្ទៃស័ក្តិ មាន៩(ប្រាំបួន)ផ្លែ ផ្ការីក៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីវល្លិ៍ជាច្រើន និងមានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង មានត្របក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

គ២: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីវល្លិ៍ មានពួរវេញពណ៌ប្រាក់១(មួយ) ឆ្នូតព័ទ្ធជុំវិញក្បាច់ភ្ញីវល្លិ៍ និងមានកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរអមពួរវេញ ជាលម្អជរជាយ

គ៣: នៅចុងខាងក្រៅបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្នូតពួរវេញពណ៌ប្រាក់១(មួយ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី៨ នៃប្រកាសនេះ។

**ឃ- អំពីស័ក្តិខ្ទាស់លើអាវ**

ស័ក្តិខ្ទាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ឃ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌ប្រាក់១(មួយ)។ នៅផ្នែកខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌ប្រាក់ "ធនាគារជាតិ នៃ កម្ពុជា"

ឃ២: មានកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ រាងកោងជាទម្រង់ស្មែងក្របីទ្រូវបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ៣: នៅផ្នែកខាងក្រោមបង្អស់ មានខ្សែពួរវេញពណ៌ប្រាក់ព័ទ្ធអម ១(មួយ) ខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការ។

ស័ក្តិខ្វាស់លើអាវនេះ ប្រើសម្រាប់ខ្វាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្វាស់លើក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្វាស់លើអាវនិងលើក្រមាពានាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី៩ នៃប្រកាសនេះ។

## ប្រការ ៧.- អំពីខ្នាតរបស់សញ្ញាស័ក្តិ

ខ្នាតរបស់សញ្ញាស័ក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងមន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានកំណត់ដូចគ្នា ដូចតទៅ៖

### ១- ខ្នាតស័ក្តិស្មា

ខ្នាតស័ក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោម៖

ចំពោះបុរស:

- មានរាងទ្រវែង និងមានចុងស្តួចរាងត្រីកោណផ្នែកខាងលើ
- មានបណ្តោយ ប្រវែង ១៣សង្ទីម៉ែត្រ
- មានទទឹងបាតក្រោម ប្រវែង ៦សង្ទីម៉ែត្រ
- មានទទឹងក ប្រវែង ៤,៥០សង្ទីម៉ែត្រ។

ចំពោះនារី:

- មានរាងទ្រវែង និងមានចុងស្តួចរាងត្រីកោណផ្នែកខាងលើ
- មានបណ្តោយ ប្រវែង ១២សង្ទីម៉ែត្រ
- មានទទឹងបាតក្រោម ប្រវែង ៥សង្ទីម៉ែត្រ
- មានទទឹងក ប្រវែង ៤សង្ទីម៉ែត្រ។

### ២- ខ្នាតស័ក្តិចុងកអាវ

ខ្នាតស័ក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោម៖

ចំពោះបុរស:

- មានរាងជាចតុកោណព្នាយ
- មានបណ្តោយ ប្រវែង ៩សង្ទីម៉ែត្រ
- មានទទឹង ប្រវែង ៤សង្ទីម៉ែត្រ។

ចំពោះនារី:

- មានរាងជាចតុកោណព្នាយ
- មានបណ្តោយ ប្រវែង ៨សង្ទីម៉ែត្រ
- មានទទឹង ប្រវែង ៣,៥០សង្ទីម៉ែត្រ។

### ៣- ខ្នាតស័ក្តិចុងដៃអាវ

ខ្នាតស័ក្តិចុងដៃអាវ ត្រូវបានកំណត់ដូចខាងក្រោម៖

ចំពោះបុរសៈ

- មានរាងបួនជ្រុងទ្រវែង
- មានបណ្តោយ ប្រវែង ៣២សង្ទីម៉ែត្រ
- មានទទឹង ប្រវែង ៩,៧០សង្ទីម៉ែត្រ។

ចំពោះនារីៈ

- មានរាងបួនជ្រុងទ្រវែង
- មានបណ្តោយ ប្រវែង ២៨សង្ទីម៉ែត្រ
- មានទទឹង ប្រវែង ៨សង្ទីម៉ែត្រ ។

### ៤- ខ្នាតស័ក្តិខ្នាស់លើអាវ

ខ្នាតស័ក្តិខ្នាស់លើអាវ ត្រូវបានកំណត់ដូចខាងក្រោម៖

- មានរាងស្លឹកពោធិ៍
- មានកម្ពស់ ប្រវែង ៦,២០សង្ទីម៉ែត្រ
- មានទទឹង ប្រវែង ៥,២០សង្ទីម៉ែត្រ ។

ដោយឡែក ស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវរបស់នារីមានទំហំតូចជាង ដូចខាងក្រោម៖

- ចំពោះស័ក្តិស្មា អាចមានទំហំ ៨០% ៨៥% ៩០% នៃទំហំស័ក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី
- ស័ក្តិចុងកអាវ មានទំហំទទឹង ៣ សង្ទីម៉ែត្រ ទៅ៣,៥០ សង្ទីម៉ែត្រ អាស្រ័យលើមាឌរបស់នារី។
- ស័ក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃទំហំទទឹងស័ក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់នារី។

## ជំពូកទី ៤
## ប្រភេទឯកសណ្ឋាន និងការប្រើប្រាស់

**ប្រការ ៨.-**

ប្រភេទឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានកំណត់ដូចខាងក្រោម៖

### ១- ឯកសណ្ឋានផ្លូវការ

#### ក- ចំពោះបុរស

- អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិ និងគ្មានឆែកខ្នង។ អាវនេះមានហោប៉ៅចំនួន៤(បួន) គឺហោប៉ៅខាងលើ ២(ពីរ)ដេរបង្កប់ មានគម្របរាងបួនជ្រុងទ្រវែង មានគែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគម្របបួនជ្រុងទ្រវែង មានគែមរាងមូល ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវរូបព្រះសង្ហារពណ៌មាស ឬពណ៌ប្រាក់ទៅតាមប្រភេទក្របខ័ណ្ឌ។ នៅចុងដៃអាវទាំងសងខាង មានឡេវបញ្ឆោតចំនួន៣(បី)រូបព្រះសង្ហារពណ៌មាស ឬពណ៌ប្រាក់ ទៅតាមប្រភេទក្របខ័ណ្ឌ។ អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ហារចំនួន៧(ប្រាំពីរ) ពណ៌មាស ឬពណ៌ប្រាក់ទៅតាមប្រភេទក្របខ័ណ្ឌ
- ខោជើងវែង មានពណ៌ទឹកប៊ិចក្រម៉ៅ ស្បែកជើងឃ្លុបពណ៌ខ្មៅ និងស្រោមជើងពណ៌ខ្មៅ។

#### ខ- ចំពោះស្ត្រី

- អាវជីបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវរបស់បុរស កតាំង គ្មានឆែកខ្នង បិទឡេវមុខ ដាក់ឡេវរូបព្រះសង្ហារចំនួន៥(ប្រាំ)ពណ៌មាស ឬពណ៌ប្រាក់ទៅតាមប្រភេទក្របខ័ណ្ឌ។ ចុងកអាវទាំងសងខាងមានស័ក្តិតាមឋានន្តរស័ក្តិ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិ គ្មានហោប៉ៅ អាវដៃវែងត្រឹមភ្នែកគោលដៃ ចុងដៃអាវមានស័ក្តិតាមឋានន្តរស័ក្តិ
- សំពត់សំឡុយអំពីអន្លូញ មានឆ្នូតពណ៌ខៀវនិងពណ៌ខ្មៅ ដែលឆ្នូតនីមួយៗ មានទំហំ១,៥០មីលីម៉ែត្រ មានសម្រុងលើភ្នែកគោលនៃស្មងជើងប្រវែងពី១០ ទៅ ១៥សង្ទីម៉ែត្រ អនុលោមទៅតាមមាឌ និងកម្ពស់
- ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែង ពណ៌សសម្រាប់ពេលព្រឹក ឬពណ៌ខ្មៅសម្រាប់ពេលល្ងាច។

រូបគំនូរឯកសណ្ឋានផ្លូវការសម្រាប់បុរស និងស្ត្រី មានគំរូដូចក្នុងឧបសម្ព័ន្ធទី១០ នៃប្រកាសនេះ។

### ២- ឯកសណ្ឋានប្រពៃណីជាតិ

#### ក- ចំពោះបុរស

- អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិនិងគ្មានឆែកខ្នង។ អាវនេះ មានហោប៉ៅចំនួន៤(បួន) គឺហោប៉ៅខាងលើ ២(ពីរ)ដេរបង្កប់ មានគម្របរាងបួនជ្រុងទ្រវែង មានគែមរាងមូល ហោប៉ៅខាងក្រោម២(ពីរ)ដេរបង្កប់ មានគម្របរាងបួនជ្រុងទ្រវែង មានគែមរាងមូល ហើយនៅលើគម្របហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ហារពណ៌មាស។ នៅចុងដៃអាវទាំងសងខាង មានឡេវបញ្ឆោតចំនួន៣(បី) រូបព្រះសង្ហារពណ៌មាស។ អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ហារចំនួន៧(ប្រាំពីរ) ពណ៌មាស

- សំពត់ជាមួងចងក្បិន ពណ៌តាមថ្ងៃ
- ស្បែកជើងឃ្លុបពណ៌ខ្មៅ កខ្លី ស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់។

**ខ- ចំពោះស្ត្រី**

- សំពត់ជាមួងចងក្បិន ពណ៌តាមថ្ងៃ ពាក់ជាមួយអាវពណ៌ស មានកមូល ដៃវែង និងមានស័ក្តិនៅចុងដៃអាវ
- ពានាក្រមាតាមពណ៌សំពត់ ឬពានាក្រមាពណ៌ស៊ីនួន [១] តាមពិធីការកំណត់
- នៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង មានខ្ទាស់សញ្ញាសម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី
- ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែងពណ៌សសម្រាប់ពេលព្រឹក ឬពណ៌ខ្មៅសម្រាប់ពេលល្ងាច
- កាបូបយួរដៃពណ៌ស ឬពណ៌ខ្មៅ (មិនឱ្យស្ពាយទេ) ស្របតាមការប្រើស្បែកជើងពណ៌ស ឬពណ៌ខ្មៅ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និងស្ត្រីដែលស្លៀកសំពត់ជាមួងចងក្បិនមានគំរូដូចក្នុងឧបសម្ព័ន្ធទី១១ នៃប្រកាសនេះ។

**ប្រការ ៩.-**

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់មន្ត្រីជាន់ខ្ពស់ និងមន្ត្រីក្រមការ ត្រូវបានកំណត់ដូចខាងក្រោម៖

- ឯកសណ្ឋានផ្លូវការសម្រាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗទៀតរបស់រដ្ឋ។
- ឯកសណ្ឋានប្រពៃណីជាតិសម្រាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និងសាសនាដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម ឬទីកន្លែងផ្សេងៗត្រូវបានកំណត់ឱ្យប្រើឯកសណ្ឋាននេះ តែមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ដែលមានឋានន្តរស័ក្តិឧត្តមមន្ត្រី។

ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះ ត្រូវស្លៀកពាក់ទៅតាមការកំណត់របស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ។

## ជំពូកទី ៥
## របបកំណត់ឯកសណ្ឋាន និងសញ្ញាស័ក្តិ

**ប្រការ ១០.-**

ការចំណាយសម្រាប់ផលិតស័ក្តិ ជាបន្ទុករបស់ធនាគារជាតិនៃកម្ពុជា។ រីឯការចំណាយសម្រាប់ឯកសណ្ឋានជាសម្លៀកបំពាក់ ស្បែកជើង និងកាបូប ជាបន្ទុករបស់សាមីខ្លួនផ្ទាល់។

[១] ពណ៌ស៊ីនួន: សម្បុរសេលាយលឿងបន្តិច សម្បុរសេលាយលឿងខ្ចីបំផុរ

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ ១១.-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១៤

**ទេសាភិបាល**

ជា-ចាន់តូ

**កន្លែងទទួល**
- ដូចប្រការ ១១
- សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ....ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## រូបសញ្ញា ធនាគារជាតិនៃកម្ពុជា

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ( ពណ៌មាស )



ស័ក្តិស្មា



ស័ក្តិករអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ ឧរៈមន្ត្រី (ពណ៌មាស)



ស័ក្តិស្មា



ស័ក្តិកអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌ
មន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ អនុមន្ត្រី ( ពណ៌មាស )



ស័ក្តិស្មា



ស័ក្តិកអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៥ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## ស័ក្តិខ្ចាស់លើដើមទ្រូង សម្រាប់មន្ត្រីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា (ពណ៌មាស)




ស័ក្តិខ្ចាស់លើអាវ
ឋានន្តរស័ក្តិឧត្តមមន្ត្រី




ស័ក្តិខ្ចាស់លើអាវ
ឋានន្តរស័ក្តិវរៈមន្ត្រី




ស័ក្តិខ្ចាស់លើអាវ
ឋានន្តរស័ក្តិអនុមន្ត្រី

ឧបសម្ព័ន្ធទី៦ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

# សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ នាយក្រមការ (ពណ៌ប្រាក់)



ស័ក្តិស្មា



ស័ក្តិករអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៧ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ ក្រមការដើមខ្សែ (ពណ៌ប្រាក់)



ស័ក្តិស្មា



ស័ក្តិករអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៨ នៃប្រកាសលេខ....ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌ
មន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ ក្រមការ (ពណ៌ប្រាក់)



ស័ក្តិស្មា



ស័ក្តិកអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៩ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## ស័ក្តិខ្លាស់លើដើមទ្រូង សម្រាប់មន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា (ពណ៌ប្រាក់)



ស័ក្តិខ្លាស់លើអាវ
ឋានន្តរស័ក្តិនាយក្រមការ



ស័ក្តិខ្លាស់លើអាវ
ឋានន្តរស័ក្តិក្រមការដើមខ្សែ



ស័ក្តិខ្លាស់លើអាវ
ឋានន្តរស័ក្តិក្រមការ

ឧបសម្ព័ន្ធទី១០ នៃប្រកាសលេខ.ធ៨.០១៤.២៣១.ប្រក.ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤.
ស្ដីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌ
មន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

# ឯកសណ្ឋានផ្លូវការ សម្រាប់មន្ត្រីធនាគារជាតិនៃកម្ពុជា



ស្ត្រី



បុរស

ឧបសម្ព័ន្ធទី១១ នៃប្រកាសលេខ.ធ៨.០១៤.២៣១.ប្រក.ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤.
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## ឯកសណ្ឋានប្រពៃណី សម្រាប់មន្ត្រីធនាគារជាតិនៃកម្ពុជា



ស្ត្រី



បុរស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០១១៤ ឧសក.កន.ប្រក.៧

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ១៨៣៥/១៤គ.វ.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន វីននី ហ្វេសិន ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន វីននី ហ្វេសិន (WINNIE FASHION CO., LTD.) តំណាងដោយ លោកស្រី LEE WING YEE សញ្ជាតិចិន(ហុងកុង) អាយុ៣៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ KJ0134193 ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ មានអាសយដ្ឋានបច្ចុប្បន្ន៖ Rm 807, Laws Commercial Plaza, 788 Cheung Sha Wan Road, Kowloon, Hong Kong. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀបំពាក់ វីននី ហេ្វសិន "*

**ទីតាំងរោងចក្រ៖** *" ភូមិត្រពាំងក្រសាំង ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មីនៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រអាចគ្រប់គ្រងរោងចក្រ ដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែ ទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។/.

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌ ទាំងឡាយនៃប្រកាសនេះ។៚

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបាន ឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខ ការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកណ្តាល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០១១៩ ឧស.ក.ស.ស.ផ.៧

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ១៣៨១/១៤ គ.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន វ៉ា ឡុង (ខេមបូឌា) អៅសូល អ៊ិនដាសស្ទ្រី ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន វ៉ា ឡុង (ខេមបូឌា) អៅសូល អ៊ិនដាសស្ទ្រី (HWA LONG (CAMBODIA) OUTSOLE INDUSTRY LTD.) តំណាងដោយ កញ្ញា LIU, HUI-CHI សញ្ជាតិចិន (តៃវ៉ាន់) អាយុ៣៥ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 301819778 ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១០ មានអាសយដ្ឋានបច្ចុប្បន្ន៖ Taiwan, China. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូច ខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១.ស្បែកជើង | ១៥២០ |
| ២.គ្រឿងបន្សំស្បែកជើង | ១៥២០ |

**ផ្លាកឈ្មោះរោងចក្រ៖** *" រោងចក្រផលិតស្បែកជើង និងគ្រឿងបន្សំស្បែកជើង វ៉ា ឡុង (ខេមបូឌា) អៅស្វូល អ៊ិនដាសស្ទ្រី "*

**ទីតាំងរោងចក្រ៖** *" ផ្លូវជាតិលេខ៦A ភូមិឈើទាល ឃុំផ្តៅជុំ ស្រុកជើងព្រៃ ខេត្តកំពង់ចាម "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជា ធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការ ផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែល បានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញ បច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃយ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួង នឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឲ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។៚

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ចាម និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពង់ចាម
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ០១៤០ ឧសក.កឧ.បក-៧

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ១១៣៣/១៣ ស.ត.ស.ព ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ញូ គ្លរី ប៊ែក & ឡាក់ហ្គីដ្យ (ខេមបូឌា) ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ញូ គ្លរី ប៊ែក & ឡាក់ហ្គីដ្យ (ខេមបូឌា) (NEW GLORY BAGS & LUGGAGE (CAMBODIA) Co., Ltd.) តំណាងដោយ លោកស្រី NI LIN សញ្ជាតិចិន អាយុ៤៥ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G58946819 ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ មានអាសយដ្ឋានបច្ចុប្បន្ន៖ Rm.1002, No. 1980 Luoxiu Rd, Minhang, Shanghai, China. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| កាបូប | ១៥១២ |

**ផ្លាកឈ្មោះរោងចក្រៈ** *" រោងចក្រផលិតកាបូប ញូ ត្លូរី បែក & ឡាក់ហ្គីដ្យ (ខេមបូឌា) "*
**ទីតាំងរោងចក្រៈ** *" តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិពូធឿង ឃុំបិតត្រាំង និងភូមិស្ទាច់ដែង ឃុំរាម) ស្រុកព្រៃនប់ ខេត្តព្រះសីហនុ "*

**ប្រការ២ៈ** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជា ធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការ ផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែល បានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣ៈ** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ៈ** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥ៈ** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញ បច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦ៈ** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧ៈ** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួង នឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឲ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពីៈ ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តព្រះសីហនុ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ